ឯកសារបណ្តុះបណ្តាល

# ការសិក្សាបែបស្ថាបនានិយម

## កម្មវិធីសាលារៀនជំនាន់ថ្មី



ភ្នំពេញ

ខែវិច្ឆិកា ឆ្នាំ២០២០

Kampuchean Action for Primary Education, PO Box 1621, Phnom Penh, Tel: 042-941-481, Fax: 042-941-918, email: kape@kapekh.org, website: www.kapekh.org

# មាតិកា


១ សេចក្តីណែនាំ ៣
១.១ ទិដ្ឋភាពទូទៅ ៣
១.២ គោលបំណង និងខ្លឹមសារឯកសារនេះ ៤
១.៣ ការអនុវត្តការសិក្សាបែបស្ថាបនានិយមនៅកម្ពុជា ៥
២ របៀបប្រើប្រាស់ឯកសារនេះ ៨
៣ ផែនការមេរៀនសម្រាប់អ្នកសម្របសម្រួល ១០
មេរៀនទី៣.១ តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី? ១១
មេរៀនទី៣.២ ការអនុវត្តការសិក្សាបែបស្ថាបនានិយមក្នុងថ្នាក់រៀន ១៩
មេរៀនទី៣.៣ ការបង្កើតបរិបទស្ថាប័នដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម ៣០
មេរៀនទី៣.៤ ការវាយតម្លៃសិស្សក្នុងថ្នាក់រៀនដែលអនុវត្តស្ថាបនានិយម ៣៧
៤ ឯកសារចែកសម្រាប់សិក្ខាកាម ៤២
**ឯកសារចែកទី ១៖** ការភ្ជាប់ការសិក្សាស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ ៤៣
**ឯកសារចែកទី ២ក៖** និយមន័យការសិក្សាបែបស្ថាបនានិយម ៤៤
**ឯកសារចែកទី ២ខ៖** គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម ៤៦
**ឯកសារចែកទី ៣៖** ហេតុអ្វីការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធិភាព? ៤៨
**ឯកសារចែកទី ៤៖** ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy ៥០
**ឯកសារចែកទី ៥ក៖** ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម ៥២
**ឯកសារចែកទី ៥ខ៖** ការបង្កើតបញ្ញត្តិពីរផ្ទុយគ្នា ៥៤
**ឯកសារចែកទី ៦៖** វិធីសាស្រ្តបង្រៀនល្អៗមួយចំនួន ក្នុងការសិក្សាបែបស្ថាបនានិយម ៥៦
**ឯកសារចែកទី ៧៖** វិធីសាស្រ្តការសិក្សាអាស្រ័យលើបញ្ហាដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម ៦៣
**ឯកសារចែកទី ៨៖** ដំណើរការ និង ផលិតផល នៃការសិក្សាបែបស្ថាបនានិយម ៦៥
**ឯកសារចែកទី ៩៖** ទ្រឹស្តីសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា ៦៨

**ឯកសារចែកទី ១០៖** ភាពផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម ៧០

**ឯកសារចែកទី ១១៖** យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម ៧១

**ឯកសារចែកទី១២៖** ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម ៧៣

# សេចក្តីផ្តើម

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅ



**ទូទៅ៖** ឯកសារនេះមានគោលបំណង ជួយអ្នកអប់រំនៅកម្ពុជាឱ្យប្តូរវិធីសាស្ត្របង្រៀនពីគំរូ "ការសិក្សាបែបអកម្ម" ដែលសិស្សត្រូវបានគេគិតថាចាំតែទទួលចំណេះដឹងពីគ្រូមកវិធីសាស្ត្រថ្មីមួយដែលសិស្សជាអ្នករៀនបង្កើតចំណេះដឹងថ្មីៗដោយខ្លួនឯង។ ទ្រឹស្តីនៃការសិក្សានេះត្រូវបានគេស្គាល់ថា "*ការសិក្សាបែបស្ថាបនានិយម*" ដែលវាជាគំនិតថ្មីមួយជួយឱ្យមានការផ្លាស់ប្តូរ។ នៅពេលប្រទេសកម្ពុជាឈានចូលដល់សតវត្សរ៍ទី ២១ មានតម្រូវការកើនឡើងជាច្រើនសម្រាប់ប្រព័ន្ធអប់រំ ដើម្បីផលិតកម្លាំងការងារដែលមានការគិតបែបស៊ីជម្រៅ អាចដោះស្រាយបញ្ហា និងចេះសហការគ្នាធ្វើការ។ យន្តការនៃវិធីសាស្ត្របង្រៀនពីអតីតកាលដែលបានផ្តោតតែលើការសិក្សាបែបទន្ទេញ ឬសូត្រតាមតែមួយមុខមិនអាចឆ្លើយតបទៅនឹងតម្រូវការទាំងអស់ខាងលើនេះបានទេ។ **ការសិក្សាបែបស្ថាបនានិយម** គឺគេបង្កើតឡើងក្នុងគោលបំណងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនោះ។

**ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀត៖** ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីមួយទូលំទូលាយ ដែលពាក់ព័ន្ធជាមួយទស្សនទានផ្សេងៗទៀត។ ក្រៅពីធាតុស្នូលសំខាន់នៃទ្រឹស្តីនេះ ដែល *សិស្សមានសមត្ថភាពក្នុងការបង្កើតបញ្ញត្តិ* នៅមានធាតុសំខាន់ៗផ្សេងទៀតនៃដែលពាក់ព័ន្ធរួមមាន ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសិក្សាបែបសហការ និងការប្រើប្រាស់បច្ចេកវិទ្យាជាដើម។ *ការសិក្សាបែបស្ថាបនានិយម* ក៏បានដាក់បញ្ចូលផងដែរនូវវិធីសាស្ត្របង្រៀនផ្សេងទៀតដែលមានគោលដៅដូចគ្នា ដូចជា ការសិក្សាអាស្រ័យលើបញ្ហា ការសិក្សាតាមការស្រាវជ្រាវ ការសិក្សាតាមបែបរិះរក ជាដើម។ ហេតុ



ដូច្នេះ ហើយការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីជម្រើសមួយដែលមានវិធីសាស្ត្របង្រៀនជាច្រើនបញ្ចូលគ្នា។

**ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា៖**



ទោះបីជាការសិក្សាបែបស្ថាបនានិយមកើតមានយូរហើយក៏ដោយ ការប្រើប្រាស់វាទើបតែបានកើនឡើងនៅពេលដែលពិភពលោកឈានចូលក្នុងយុគសម័យបច្ចេកវិទ្យាប៉ុណ្ណោះ។ បច្ចេកវិទ្យាព័ត៌មានវិទ្យា បានបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្រសិក្សាបែបស្ថាបនានិយម ក្នុងការលើកកម្ពស់ការសិក្សាបែបសហការ (ដូចជា៖ តាមរយៈបណ្តាញកុំព្យូទ័រ) ដើម្បីរៀបចំ និងសំយោគព័ត៌មានថ្មីៗ (ដូចជា៖ តាមរយៈការប្រើប្រាស់ Power Point) និងដើម្បីដោះស្រាយបញ្ហា (ឧ. តាមរយៈកម្មវិធីគ្រប់គ្រងនិងរៀបចំទិន្នន័យ ជាដើម)។ ដូច្នេះហើយការប្រើប្រាស់បច្ចេកវិទ្យា ជាឧបករណ៍ដ៏សំខាន់មួយដើម្បីជួយសិស្សឱ្យអាចបង្កើតបញ្ញត្តិថ្មីៗបាន ដែលចំណុចនេះ ជាធាតុស្នូលសំខាន់នៃវិធីសាស្ត្រការសិក្សាបែបស្ថាបនានិយម។ ការបង្កើតបញ្ញត្តិនេះ គឺសំខាន់ណាស់ដើម្បីជំរុញឱ្យមាន*ការគិតបែបស៊ីជម្រៅ* ដែលជាបំណិនចាំបាច់មួយសម្រាប់ទីផ្សារការងារក្នុងយុគសម័យថ្មីនេះ។ ដូច្នេះហើយ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាង **ការសិក្សាបែបស្ថាបនានិយម បច្ចេកវិទ្យា** និង**តម្រូវការនៃទីផ្សារការងារនៅសតវត្សរ៍ទី ២១** នេះ ។

**ក្រុមគោលដៅ៖** ក្រុមគោលដៅសម្រាប់កម្មវិធីបណ្តុះបណ្តាលដែលបរិយាយក្នុងឯកសារនេះ គឺសម្រាប់គ្រូនៅកម្រិតមធ្យមសិក្សាដែលបង្រៀនសិស្សនៅថ្នាក់ទី៧ដល់ថ្នាក់ទី១២។ តែទោះជាយ៉ាងក្តី ខ្លឹមសារនៃកម្មវិធីបណ្តុះបណ្តាលនេះក៏អាចយកទៅប្រើប្រាស់សម្រាប់គ្រូបង្រៀននៅកម្រិតណាក៏បានដែរ។ ឯកសារនេះមានបំណងជួយគ្រូឱ្យមានស្តង់ដាបង្រៀនតាមតម្រូវការនៃការអប់រំនៅសតវត្សរ៍ទី២១ ដោយផ្លាស់ប្តូរការបង្រៀនបែបវិធីសាស្ត្រឧទ្ទេសមកជាអ្នកសម្របសម្រួលការសិក្សាវិញ។

## ១.២ គោលបំណង និងខ្លឹមសារឯកសារនេះ

ឯកសារបច្ចុប្បន្ននេះត្រូវបានបង្កើតឡើងជាឯកសារបំប៉នគ្រូបង្គោល (Training of Trainers -ToT) ដើម្បីជួយគ្រូនៅកម្រិតមធ្យមសិក្សាឱ្យអាចប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀនរបស់ពួកគេបាន។ ជាពិសេស ឯកសារនេះគឺជាតម្រូវការដើម្បីជួយគ្រូឱ្យ

ផ្តោតលើការលើកកម្ពស់បំណិនការគិតកម្រិតខ្ពស់ដែលមានបំណិនវិភាគ សំយោគ និងបង្កើតថ្មីនៅពេលបង្រៀនគ្រប់មុខវិជ្ជាទាំងអស់។

ឯកសារនេះមានផែនការបង្រៀនតាមផ្នែក សម្រាប់គ្រូឧទ្ទេសងាយស្រួលប្រើប្រាស់ក្នុងការធ្វើបទបង្ហាញណែនាំគ្រូនូវបញ្ញត្តិមូលដ្ឋាននៃការសិក្សាបែបស្ថាបនានិយម។ ផ្នែកនីមួយៗនៃផែនការបង្រៀនមានបញ្ជាក់ពីពេលវេលា ល្បះសំខាន់ៗ ឯកសារ និងសម្ភារៈចាំបាច់ដែលត្រូវត្រៀម និងគោលបំណងនៃការសិក្សា។ ឯកសារនេះក៏មានភ្ជាប់មកជាមួយនូវឯកសារសម្រាប់សិក្ខាកាមដែលចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនេះ ដូច្នេះហើយ ពួកគាត់អាចប្រើប្រាស់ឯកសារទាំងនេះជាឯកសារយោង បន្ទាប់ពីបញ្ចប់វគ្គសិក្ខាសាលាបណ្តុះបណ្តាលនេះ។

**ខ្លឹមសារពាក់ព័ន្ធ៖** ខ្លឹមសារនៃឯកសារនេះត្រូវបានរៀបចំដោយមានលទ្ធផលរំពឹងទុកដូចខាងក្រោម៖

- សិក្ខាកាមអាចកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម និងគោលការណ៍សំខាន់ៗ
- សិក្ខាកាមអាចបង្ហាញថាពួកគេយល់ពីរបៀបប្រើប្រាស់សកម្មភាពជាក់ស្តែងក្នុងការអនុវត្តគោលវិធីការសិក្សាបែបស្ថាបនានិយមនេះ ។
- សិក្ខាកាមអាចពន្យល់ពីវិធីកាន់តែងាយស្រួលក្នុងការអនុវត្តសកម្មភាពផ្សេងៗតាំងពីដើមដល់បញ្ចប់មេរៀនណាមួយដោយប្រើការសិក្សាបែបស្ថាបនានិយម និងពីភាពចាំបាច់ដើម្បីវាយតម្លៃចំណេះដឹងសិស្សដោយប្រើប្រាស់ការវាយតម្លៃស្តង់ដា។
- សិក្ខាកាមអាចពន្យល់បានពីរបៀបរៀបចំបរិបទស្ថាប័ននៅតាមសាលារៀនរបស់ពួកគេដើម្បីជំរុញការសិក្សាតាមបែបស្ថាបនានិយម។

## ១.៣ ការអនុវត្តការសិក្សាបែបស្ថាបនានិយមក្នុងប្រទេសកម្ពុជា

ឯកសារបច្ចុប្បន្ននេះរៀបចំឡើងជាពិសេសសម្រាប់គ្រូក្នុង *កម្មវិធីសាលារៀនជំនាន់ថ្មី* ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដែលមាននៅសាលា និងអ្នកដែលចូលចិត្តធ្វើការពិសោធនូវរបៀបបង្រៀនថ្មីៗ។ ទោះបីជាបច្ចេកវិទ្យាមិនត្រូវបានប្រើប្រាស់គ្រប់ពេលសម្រាប់ថ្នាក់រៀនតាមបែបស្ថាបនានិយមក៏ដោយ ក៏វាអាចជួយពង្រីកការអនុវត្តវិធីសាស្ត្រស្ថាបនានិយមឱ្យកាន់តែមានប្រសិទ្ធិភាព



ដូចដែលបានរៀបរាប់ខាងលើ។ ការប្រើប្រាស់បច្ចេកវិទ្យា គឺសំដៅលើការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ម៉ាស៊ីន LCD បញ្ចាំងស្លាយ ឧបករណ៍សិក្សាចល័ត និងកម្មវិធីអប់រំថ្មីៗដែលសមស្រប ទៅនឹងការសិក្សាបែបសកម្ម។ ស្រដៀងគ្នានេះដែរ គ្រូក្នុងសាលារៀនរដ្ឋដែលមិនស្ថិតនៅក្នុង កម្មវិធី សាលារៀនជំនាន់ថ្មី ក៏អាចយកទៅអនុវត្តបានដែរចំពោះការសិក្សាបែបស្ថាបនានិយមនេះសម្រាប់ ថ្នាក់រៀនរបស់ពួកគេ ទោះបីជាមិនទាន់មានបច្ចេកវិទ្យាប្រើប្រាស់គ្រប់គ្រាន់ក៏ដោយ។ គ្រូត្រូវពិភាក្សា ជាមួយ នាយកសាលា និងសហការីផ្សេងទៀត នូវរបៀបអនុវត្តគោលវិធីបែបស្ថានានិយមនេះដោយ ផ្អែកទៅលើសេចក្តីណែនាំដែលបានបង្ហាញនៅក្នុងឯកសារនេះ។

ជាចុងក្រោយ សូមចងចាំថា ឯកសារនេះគ្រាន់តែជាការណែនាំខ្លីមួយ សម្រាប់គោលការណ៍ អនុវត្តការសិក្សាបែបស្ថាបនានិយមប៉ុណ្ណោះ។ គ្រូបង្រៀនជាច្រើនចំណាយពេលច្រើនខែ និងឆ្នាំក្នុង ការកែលម្អសមត្ថភាពរបស់គេក្នុងការអនុវត្តគោលការណ៍ទាំងនេះឱ្យមានប្រសិទ្ធិភាពក្នុងថ្នាក់រៀន។ ហេតុដូច្នេះហើយ អ្នកត្រូវចងចាំថា ខណៈដែលឯកសារនេះអាចមានប្រយោជន៍សម្រាប់គ្រូស្គាល់ ត្រួសៗ ពីគោលការណ៍សិក្សាបែបស្ថាបនានិយម វាទាមទាឱ្យមានការអនុវត្ត និងសិក្សាស្វែងយល់ ច្រើនឆ្នាំបន្ថែមទៀតដើម្បីឱ្យមានការស្ទាត់ជំនាញលើបច្ចេកទេសដែលបានបង្ហាញ។

* * * * * * * * * * * * * * * * *

# របៀបប្រើប្រាស់ ឯកសារនេះ

# ២. របៀបប្រើប្រាស់ឯកសារនេះ

ឯកសារនេះប្រើប្រាស់និមិត្តសញ្ញាស្តង់ដាដូចខាងក្រោមដើម្បីងាយស្រួលប្រើប្រាស់តាមដែលអាចធ្វើទៅបានសម្រាប់គ្រូឧទ្ទេស។ និមិត្តសញ្ញាទាំងនេះ បង្ហាញពីប្រភេទសកម្មភាពផ្សេងៗដើម្បីប្រើប្រាស់ជាមួយសិក្ខាកាមសម្រាប់ជំហាននីមួយៗនៃផែនការមេរៀន។

**រយៈពេលបង្រៀន**

**ការរៀបចំមុនពេលបណ្តុះបណ្តាល៖** មានព័ត៌មានពីការរៀបចំផ្នែកផ្សេងៗដែលត្រូវបំប៉ន ហើយវាបង្ហាញផងដែរពីសម្ភារៈ និងការប្រើប្រាស់វាសម្រាប់សកម្មភាពទាំងនោះ។

**សម្ភារឧបទ្ទេស៖** ផ្នែកនេះបង្ហាញពីសម្ភារៈចាំបាច់សម្រាប់ការបំប៉ន។ សម្ភារៈដែលយើងត្រូវការជាងគេនោះភាគច្រើនគឺ ប៊ិក និងក្រដាស។ សម្ភារៈផ្សេងទៀត គឺមាននៅក្នុងមេរៀនបំប៉នសម្រាប់សិក្ខាកាមដែលបានភ្ជាប់ក្នុងឯកសារនេះស្រាប់។

**លទ្ធផលរំពឹងទុក៖** បង្ហាញពីអ្វីដែលរំពឹងថាសិក្ខាកាមនឹងទទួលបាន និងការវាយតម្លៃនៅពេលបញ្ចប់ការបំប៉ននេះ។

## និមិត្តសញ្ញាបង្ហាញពីជំហាន និងដំណើរការ

ផ្នែកទី៣ នៃឯកសារនេះ ផ្តល់លំដាប់លំដោយមេរៀនស្តីពីរបៀបបំប៉នគ្រូបង្រៀន ដែលរំពឹងប្រើប្រាស់បច្ចេកទេសការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀន។ និមិត្តសញ្ញាខាងក្រោមនឹងប្រាប់អ្នកសម្របសម្រួលភ្លាមៗ ពីសកម្មភាពជាក់ស្តែងដែលត្រូវរៀបចំផែនការបំប៉ននេះ។ ផ្នែកនៃឯកសារនេះរួមបញ្ចូលទាំងសកម្មភាពត្រូវធ្វើ សំណួរត្រិះរិះ ឧទាហរណ៍ដើម្បីបញ្ជាក់ពីការអនុវត្តលំហាត់ និងកិច្ចការផ្សេងៗទៀត។ ទោះបីជា វាជាការចាំបាច់ដែលអ្នកត្រូវអានមេរៀនទាំងមូលឱ្យបានយល់ច្បាស់ ពិសេសគឺការបំប៉នលើកទី ១ គ្រូឧទ្ទេសអាចដឹងយ៉ាងងាយស្រួលនូវអ្វីដែលគាត់ត្រូវធ្វើ ដោយមើលនិមិត្តសញ្ញាដែលប្រើប្រាស់ក្នុងឯកសារនេះ។

**សកម្មភាពត្រូវធ្វើ៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវធ្វើសកម្មភាពដូចជាការចែកឯកសារឱ្យទៅសិក្ខាកាម រៀបចំតុកៅអីឱ្យមានសណ្តាប់ធ្នាប់ និងការបែងចែកក្រុមពិភាក្សាជាដើម។

**ការសួរសំណួរ៖** នេះបង្ហាញថាអ្នកសម្របសម្រួលត្រូវសួរសំណួរសំខាន់ៗទៅសិក្ខាកាមដូចជាការផ្តើមសកម្មភាព ឬពិភាក្សា។

**ការពិភាក្សា៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវដឹកនាំការពិភាក្សា ឬ អនុញ្ញាតឱ្យអ្នកចូលរួមពិភាក្សាអ្វីមួយក្នុងក្រុមរបស់ពួកគេ។

**កិច្ចការសរសេរ៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកចូលរួមត្រូវសរសេរអ្វីមួយនៅលើក្រដាសប៉ុស្ទ័រ បំពេញលំហាត់ ឬកិច្ចការសរសេរផ្សេងទៀត។

**ការពន្យល់៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវពន្យល់ដល់សិក្ខាកាម។

* * * * * * * * * * * * * * * * *

# ផែនការមេរៀន
# សម្រាប់
# អ្នកសម្របសម្រួល

# មេរៀនទី៣.១ តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី?

**រយៈពេលបង្រៀន៖** ២ម៉ោង និង៣០នាទី

**ការត្រៀមលក្ខណៈរបស់គ្រូឧទ្ទេស៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននេះនៅលើក្រដាសប៉ុស្ទ័រណែនាំមេរៀន។
- ថតចម្លង**ឯកសារទី ១៖** *ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ*
- ថតចម្លង**ឯកសារទី ២ក៖** *និយមន័យការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារទី ២ខ៖** *គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារទី ៣៖** *ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធិភាព*
- សរសេរគោលការណ៍សិក្សាបែបស្ថាបនានិយមនីមួយៗ (បង្ហាញក្នុងឯកសារទី២ខ) ចូលក្នុងក្រដាសប៉ុស្ទ័រ (ពាក់កណ្ដាលខាងលើ) ដោយទុកកន្លែងចំហរខាងក្រោមនៃក្រដាសនីមួយៗសម្រាប់សិក្ខាកាមសរសេរឧទាហរណ៍។

**សម្ភារឧបទ្ទេសដែលត្រូវការ៖**

- ក្រដាសប៉ុស្ទ័រ ហ្វឺតសរសេរ
- ក្រដាសប៉ុស្ទ័រដែលសង្ខេបពីលទ្ធផលរំពឹងទុករបស់មេរៀន។
- **ឯកសារទី១៖** ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ
- **ឯកសារទី២ក៖** និយមន័យការសិក្សាបែបស្ថាបនានិយម
- **ឯកសារទី២ខ៖** គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម
- **ឯកសារទី៣៖** ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធិភាព
- ក្រដាសប៉ុស្ទ័រដែលបានសរសេរគោលការណ៍សំខាន់ៗនៃស្ថាបនានិយម

## លទ្ធផលសិក្សាៈ

- អ្នកចូលរួមអាច**ពន្យល់**គោលការណ៍សំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម ពិសេសទំនាក់ទំនងរវាងទ្រឹស្តីស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងទៀត
- អ្នកចូលរួមអាច**ផ្តល់ឧទាហរណ៍**ពីសកម្មភាពជាក់ស្តែងពីគោលការណ៍សំខាន់ៗ នៃការសិក្សាបែបស្ថាបនានិយម។
- អ្នកចូលរួមអាច**បង្កើតដ្យាក្រាមដែល**បកស្រាយពីទំនាក់ទំនងរវាងគោលការណ៍សំខាន់ៗ នៅក្នុងការសិក្សាបែបស្ថាបនានិយម
- អ្នកចូលរួមអាច**ពន្យល់**ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធិភាពចំពោះការបង្កើនការចងចាំ និងយល់ដឹងបានល្អ។
- អ្នកចូលរួមអាច**កំណត់**បាននូវសកម្មភាព "ការចូលរួមសកម្ម" ដែលនឹងជំរុញការកាត់បន្ថយសកម្មភាពអកម្មបានច្រើន។

* * * * * * * * * * * * * * * * *

# ផែនការមេរៀន

## វត្ថុបំណងមេរៀន

បិទក្រដាសប៉ុស្ទ័រនៅលើក្តារខៀនដែលសង្ខេបពីវត្ថុបំណងឬការរំពឹងទុករបស់មេរៀន។ ពន្យល់ពីលទ្ធផលរំពឹងទុក និងអ្វីដែលអ្នកចូលរួមអាចធ្វើបាននៅពេលបញ្ចប់មេរៀន។

## ការណែនាំទ្រឹស្តីស្ថាបនានិយមជាទ្រឹស្តីដែលបញ្ចូលគ្នារវាងទ្រឹស្តីសិក្សាផ្សេងៗជាច្រើន

អ្នកសម្របសម្រួលត្រូវតែចាប់ផ្តើមផ្នែកនេះជាមួយការពន្យល់ពីគំនិតសំខាន់ៗ នៃការសិក្សាបែបស្ថាបនានិយម ដោយចេញពីពាក្យ "ស្ថាបនា"។ នោះមានន័យថា **ស្ថាបនានិយមគឺការសិក្សាផ្តោតទៅលើការស្ថាបនា ឬបង្កើតបញ្ញត្តិ។**

**ការសិក្សាបែបស្ថាបនានិយម** គឺជាទ្រឹស្តីមួយដែលបូកបញ្ចូលទ្រឹស្តីសិក្សាផ្សេងៗទៀតជាច្រើន។ នេះរួមបញ្ចូលការបង្កើតបញ្ញត្តិ (គោលការណ៍ស្នូល) ការសហការក្នុងក្រុម ការឆ្លុះបញ្ចាំងពីបទពិសោធន៍ពីមុន តួនាទីរបស់បច្ចេកវិទ្យា ការស្រមៃ និងកត្តាផ្សេងៗទៀតជាច្រើន។

ចែក **ឯកសារទី១៖** "ការផ្សាភ្ជាប់ទ្រឹស្តីស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀតដើម្បីបង្ហាញពីទំនាក់ទំនងរបស់វា។




បន្ទាប់មក គ្រូឧទ្ទេសត្រូវដឹកនាំការពិភាក្សាពីគោលការណ៍សំខាន់ៗដែលបង្ហាញក្នុងដ្យាក្រាមខាងលើ សួរថាតើទ្រឹស្តីទាំងនេះពាក់ព័ន្ធទៅនឹងគោលការណ៍នៃការសិក្សាបែបស្ថាបនានិយមដូចម្តេច? សូមកុំព្យាយាមបង្ហាញព័ត៌មាននេះដោយផ្ទាល់ដល់អ្នកចូលរួម ប៉ុន្តែត្រូវធ្វើការសំយោគចម្លើយរបស់អ្នកចូលរួម។ អ្នកសម្របសម្រួលត្រូវតែ

ពិនិត្យមើលថាតើអ្នកចូលរួមបានយល់ដឹងពីទ្រឹស្តីផ្សេងៗទៀតកម្រិតណាដែរ (ឧ. ការសិក្សាតាមបែបរិះរក ការសិក្សាអាស្រ័យលើបញ្ហា។ល។) សំណួរគន្លឹះខ្លះត្រូវបានផ្តល់ឱ្យខាងក្រោមនៃ **ឯកសារទី១**។

អំឡុងពេលសកម្មភាព *សួរ និងឆ្លើយសំណួរ* សូមប្រើប្រាស់ព័ត៌មានខាងក្រោមដើម្បីជួយអ្នកចូលរួមឆ្លើយសំណួរបានត្រឹមត្រូវដោយមិនចាំបាច់ប្រាប់ត្រង់ៗ៖

- ***ការសិក្សាអាស្រ័យលើបញ្ហា៖*** ការដោះស្រាយបញ្ហាទាមទារឱ្យយើងត្រូវឆ្លុះបញ្ចាំងបទពិសោធន៍ធ្លាប់ដឹង និងបរិបទថ្មីដើម្បីស្វែងរក ឬ "ស្ថាបនា" គំនិតថ្មីមួយដែលអាចដោះស្រាយបញ្ហានោះបាន។ ការឆ្លុះបញ្ចាំងបទពិសោធន៍ដែលធ្លាប់ជួបរបស់នរណាម្នាក់ពីមុនដើម្បីស្វែងរកគំនិតថ្មីៗ គឺជាគោលការណ៍ស្នូលនៃទ្រឹស្តីការសិក្សាបែបស្ថាបនានិយម។
- ***ការសិក្សាតាមបែបរិះរក៖*** ការសិក្សាបែបស្ថាបនានិយមលើកកម្ពស់គំនិតដែលថាយើងអាចចងចាំអ្វីៗ កាន់តែល្អ ប្រសិនបើយើងរិះរកវាដោយខ្លួនឯងតាមរយៈការពិភាក្សា ការពិសោធន៍ និងយុទ្ធសាស្រ្តសិក្សាបែបសកម្មផ្សេងៗទៀត។
- **ប៊្លូមតាក់សូណូមី**(*Bloom's Taxonomy*)៖ ការសិក្សាបែបស្ថាបនានិយមផ្តោតខ្លាំងលើបំណិនការគិតកម្រិតខ្ពស់ រួមមានការវិភាគ វាយតម្លៃ និងបង្កើតថ្មី។
- ***ការគិតពិចារណាស៊ីជម្រៅ៖*** ការវិភាគ ការវាយតម្លៃ និងបង្កើតថ្មីគឺជាបំណិនសំខាន់ៗ ក្នុងការគិតបែបស៊ីជម្រៅ។
- ***ការសហការ៖*** ការធ្វើការងារជាមួយអ្នកផ្សេងទៀតក្នុងក្រុមដើម្បីផ្លាស់ប្តូរគំនិតយោបល់គ្នាអាចធ្វើទៅបាន លុះត្រាតែតាមរយៈ *ការពិភាក្សា* ហើយ *ការពិភាក្សា* នេះនាំឱ្យមានការបង្កើតបញ្ញត្តិ និងជំរុញឱ្យសិស្សអាចសំយោគគំនិតប្លែកៗ ។
- ***បច្ចេកវិទ្យា៖*** បច្ចេកវិទ្យាព័ត៌មានវិទ្យា បានជួយបង្កើនប្រសិទ្ធិភាពនៃការសិក្សាបែបស្ថាបនានិយម ដើម្បីលើកកម្ពស់ *ការសិក្សាបែបសហការ* (ឧទាហរណ៍៖ តាមរយៈបណ្តាញ Network) *សិស្សបង្កើត និងសំយោគព័ត៌មានថ្មីៗ* (ឧទាហរណ៍៖ តាមរយៈការធ្វើបទបង្ហាញ PowerPoint) និង *ដោះស្រាយបញ្ហាផ្សេងៗ* (ឧទាហរណ៍៖ តាមរយៈកម្មវិធីគ្រប់គ្រងនិងរៀបចំទិន្នន័យ ជាដើម)។ ដូច្នេះការប្រើប្រាស់បច្ចេកវិទ្យា ជាឧបករណ៍ដ៏សំខាន់មួយដើម្បីជួយសិស្សឱ្យ

អាចបង្កើតបញ្ញត្តិបាន ដែលចំណុចនេះ ជាធាតុស្នូលសំខាន់នៃគោលវិធីសិក្សាបែបស្ថាបនានិយម។

## ការកំណត់និយមន័យស្ថាបនានិយម និងគោលការណ៍សំខាន់ៗដែលគាំទ្រទ្រឹស្តីនេះ

ចាប់ផ្តើមចំណុចនេះដោយចែក **ឯកសារទី២ក៖** "ការកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម"។

ត្រូវពន្យល់ដោយបញ្ជាក់ឱ្យច្បាស់ថា ការសិក្សាបែបស្ថាបនានិយមទាមទារឱ្យមានការបង្កើតបញ្ញត្តិថ្មីៗដោយសិស្សផ្ទាល់។ ពេលបង្ហាញបញ្ហាណាមួយ សិស្សឆ្លុះបញ្ចាំងបញ្ហានេះ ដោយប្រៀបធៀបទៅនឹងបទពិសោធន៍ដែលធ្លាប់ជួប និងចុងក្រោយបង្កើតបញ្ញត្តិថ្មី។

### តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី?

- ការសិក្សាសកម្ម & ដឹកនាំខ្លួនឯង
- កសាងចំណេះដឹងថ្មីដោយផ្អែកទៅលើចំណេះដឹងមានស្រាប់ និងបទពិសោធន៍
- ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងបញ្ញត្តិផ្សេងៗដើម្បីបង្កើតបញ្ញត្តិថ្មីៗ
- ការផ្លាស់ប្តូរគំនិតគ្នាតាមរយៈការសហការជំរុញឱ្យមានដំណើរការបង្កើតគំនិតថ្មី



*"ការបង្កើតបញ្ញត្តិថ្មីៗតាមរយៈការសហការ និងផ្លាស់ប្តូរគំនិតគ្នា"*

យើងអាចបង្ហាញដំណើរការនេះដោយសរសេររូបមន្តនៅលើក្តារខៀន៖

**ការដឹកនាំខ្លួនឯង+ការឆ្លុះបញ្ចាំងពីបញ្ហា/ចំណេះដឹងពីមុន+ការសហការ = ការសិក្សាបែបស្ថាបនានិយម**

សាកល្បងធ្វើឧទាហរណ៍ដែលបង្ហាញពីដំណើរការខាងលើនេះជាមួយគ្នា។

ឧទាហរណ៍៖ ចូរឱ្យឧទាហរណ៍ផ្សេងៗ នៃសទិសភាព (Analogy)៖

**ឧទាហរណ៍៖** *ឪពុក* *ជាគូនឹង* *កូនប្រុស* *ដូចដែល* *ម្តាយ* *ជាគូនឹង* *កូនស្រី*

ប្រើប្រាស់ឧទាហរណ៍ខាងលើ សួរអ្នកចូលរួមឱ្យបង្កើតសទិសភាពផ្សេងទៀតឱ្យបាន ៤ ដែលបង្ហាញទំនាក់ទំនងស្រដៀងគ្នា។ លំហាត់ទាក់ទងនឹងចំណុចនេះត្រូវបានពន្យល់បន្ថែមក្នុង **ឯកសារទី ២ក**។

ផ្តល់ឱ្យអ្នកចូលរួមប្រហែលជា១៥នាទី សម្រាប់ការធ្វើលំហាត់នេះ និងបន្ទាប់មកឱ្យក្រុមនីមួយៗ សរសេរពីសទិសភាពដែលបង្កើតបាននៅលើក្តារខៀន ឬក្រដាសប៉ុស្ទ័រ។ បន្ទាប់មកទៀត ឱ្យអ្នកចូលរួមបំពេញលំហាត់បន្ថែមទៀត ដែលបង្ហាញពីដំណើរការវិភាគសទិសភាព។

បន្ទាប់ពីការពិភាក្សារយៈពេលខ្លីអំពីសទិសភាពរួចមក អនុវត្តការវិភាគពីធាតុផ្សេងៗនៃការសិក្សាបែបស្ថាបនានិយមដែលលំហាត់នេះបានបង្ហាញ។ ធ្វើកិច្ចការនេះជាក្រុមធំ។ ឧទាហរណ៍៖ សួរអ្នកចូលរួមនូវសំណួរដឹកនាំដូចខាងក្រោម៖

- តើផ្នែកណានៃលំហាត់នេះបង្ហាញពី "ការដឹកនាំខ្លួនឯង"?
  ***ចម្លើយ៖*** *អ្នកចូលរួមជ្រើសរើសគូសទិសភាពដោយខ្លួនឯង។*
- តើផ្នែកណានៃលំហាត់នេះបង្ហាញពី "ការឆ្លុះបញ្ចាំង" ដោយប្រើប្រាស់ចំណេះដឹងពីមុន?
  ***ចម្លើយ៖*** *អ្នកចូលរួម ឆ្លុះបញ្ចាំងលើឧទាហរណ៍ដែលផ្តល់ដោយអ្នកសម្របសម្រួល ហើយពួកគាត់អនុវត្តចំណេះដឹងនេះទៅការបង្កើតគូសទិសភាពថ្មី។*
- តើផ្នែកណានៃលំហាត់នេះបង្ហាញពី "ការសហការ"?
  ***ចម្លើយ៖*** *អ្នកចូលរួមបានពិភាក្សាក្នុងក្រុម បង្កើតបានសទិសភាពផ្សេងៗជាច្រើន ដែលមានភាពល្អប្រសើរជាងការធ្វើការជាបុគ្គល។*

លំហាត់នេះជាឧទាហរណ៍គំរូមួយនៃការសិក្សាបែបស្ថាបនានិយម។

## គោលការណ៍សំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម

សរសេរគោលការណ៍សំខាន់ៗ ៥ ដែលជាមូលដ្ឋាននៃការសិក្សាបែបស្ថាបនានិយម នៅលើក្តារខៀន។

ផ្តល់ការពន្យល់ពីគោលការណ៍នីមួយៗ ផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យក្នុង **ឯកសារទី២ខ** ប៉ុន្តែកុំផ្តល់ឧទាហរណ៍។ សូមកុំចែកឯកសារ នៅដំណាក់កាលបំប៉ននេះ។

បន្ទាប់មក ចែកក្រដាសប៉ុស្ទ័រដោយសរសេរគោលការណ៍សិក្សាបែបស្ថាបនានិយមនៅលើនោះ។ ក្រុមនីមួយៗត្រូវតែទទួលក្រដាសមួយ ឬពីរសន្លឹកដោយសរសេរគោលកាណ៍លើនោះ និងកន្លែងទំនេរខ្លះនៅខាងក្រោមសម្រាប់ជាឧទាហរណ៍។

> **ការសិក្សាបែបអន្តរកម្ម** – តាមធម្មជាតិ មនុស្សរៀន និងធ្វើការដោយមានការសហការគ្នាក្នុងជីវិតរស់នៅរបស់គេៗ អន្តរកម្ម ផ្តល់វិធីដើម្បីលើកទឹកចិត្តនិងជំរុញដល់អ្នកសិក្សា។
>
> *ផ្តល់ឧទាហរណ៍ខ្លះពីគោលការណ៍នេះនៅកន្លែងការងារ៖*
>
> - ???
> - ???
> - ???

ឱ្យអ្នកចូលរួមឱ្យសរសេរឧទាហរណ៍ពីរ ឬបីដែលបង្ហាញពីគោលការណ៍នីមួយៗនៅខាងក្រោមនៃសន្លឹកនីមួយៗ។ ផ្តល់ឱ្យពួកគេរយៈពេល៥ទៅ១០នាទី សម្រាប់សកម្មភាពនេះ ហើយពិភាក្សាជាក្រុមធំលើឧទាហរណ៍របស់ក្រុមនីមួយៗ។

បន្ទាប់មក ចែក**ឯកសារទី២ខ៖** គោលការណ៍គន្លឹះរបស់ការសិក្សាបែបស្ថាបនានិយម និងប្រៀបធៀបឧទាហរណ៍ដែលបានផ្តល់ឱ្យក្នុងឯកសារជាមួយនឹងអ្វីដែលក្រុមនីមួយៗបានបង្កើត។ ព្យាយាមសម្រួលឱ្យស៊ីគ្នាចំពោះគំនិតដែលខុសប្លែក។

***លំហាត់ជម្រើស៖*** ប្រសិនបើអ្នកចូលរួមទំនងជាយល់គំនិត និងគោលការណ៍ដែលបានបង្ហាញនេះ ពួកគេអាចបង្កើតដ្យាក្រាមបង្ហាញពីទំនាក់ទំនងរវាងធាតុសំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម។ លំហាត់នេះត្រូវបានពន្យល់ក្នុង **ឯកសារទី២ខ**។ ចែកក្រដាសផ្ទាំងធំៗដល់ក្រុមនីមួយៗសម្រាប់គូសដ្យាក្រាម។ ប្រសិនបើអ្នកចូលរួមទំនងជាអាចធ្វើលំហាត់នេះបាន ផ្តល់ពេល៣០នាទី ឱ្យពួកគេបង្កើតដ្យាក្រាមដែលពន្យល់ពីធាតុសំខាន់ៗនៃការសិក្សាបែបស្ថាបនានិយមនោះ។ ឱ្យក្រុមនីមួយៗបង្ហាញពីដ្យាក្រាមរបស់គេ និងហេតុផលនៃចម្លើយផង។



## ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធិភាព

ចែក**ឯកសារទី៣៖** "ហេតុអ្វីបានជាការសិក្សាបែបស្ថាបនាមានប្រសិទ្ធិភាព?"។ បន្ទាប់មក អ្នកសម្របសម្រួលត្រូវពន្យល់ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាពបំផុតសម្រាប់ដំណើរការរៀនសូត្រ ដោយផ្តោតលើសកម្មភាពដែលសកម្មជាងអកម្ម? បង្ហាញកម្រិតនៃការ "ចងចាំ" កើនឡើងចេញពីសកម្មភាពបែបអកម្មមកសកម្ម។ នេះអាចឃើញយ៉ាងច្បាស់នៅក្នុងរូបភាពដែលបានផ្តល់ឱ្យ។

អ្នកសម្របសម្រួលត្រូវពន្យល់បន្ថែមថា សកម្មភាពអកម្មដូចជាការអានក៏មានក្នុងដំណើរការសិក្សាដែរ តែដំណើរការសិក្សាទាំងនេះគួរបន្ថែមសកម្មភាពបែបសកម្មផ្សេងៗទៀតដែលជាឧទាហរណ៍នៃការអនុវត្តគោលវិធីបែបស្ថាបនានិយម ដែលផ្តល់ឱកាសឱ្យសិស្សមានគំនិតច្នៃប្រឌិតបង្កើតបញ្ញត្តិថ្មី ។ នៅក្នុងក្រុម សុំឱ្យអ្នកចូលរួម កំណត់សកម្មភាពផ្សេងៗដែលបង្ហាញពី "ភាពសកម្ម" និងឧទាហរណ៍មកបង្ហាញគោលការណ៍ការសិក្សាបែបស្ថាបនានិយមផង។ អ្នកចូលរួមត្រូវយល់ឱ្យច្បាស់ពីសកម្មភាពនីមួយៗ។ ផ្តល់ពេលប្រហែលជា ១៥នាទីសម្រាប់ធ្វើលំហាត់ ហើយពិភាក្សាពីសកម្មភាពនីមួយៗដែលអ្នកចូលរួមបានកំណត់។



# មេរៀនទី៣.២ - ការអនុវត្តការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀន

**រយៈពេលបង្រៀន៖** ៣ម៉ោង និង ៣០នាទី

**ការត្រៀមលក្ខណៈ**

- សរសេរវត្ថុបំណងមេរៀននៅលើក្រដាសប៉ុស្ទ័រដើម្បីណែនាំមេរៀន។
- ថតចម្លង **ឯកសារទី៤៖** *ការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងBloom's Taxonomy*
- ថតចម្លង **ឯកសារទី៥ក៖** *ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៥ខ៖** *ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ*
- ថតចម្លង **ឯកសារទី៦៖** *វិធីសាស្ត្របង្រៀនខ្លះៗ ដែលមានប្រយោជន៍នៃការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៧៖** *វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហាដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ក្រដាសប៉ុស្ទ័រ ហ្វឺត
- ក្រដាសប៉ុស្ទ័រដែលសង្ខេបវត្ថុបំណងមេរៀន។
- ថតចម្លង **ឯកសារទី៤៖** ការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy
- ថតចម្លង **ឯកសារទី៥ក៖** ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម
- ថតចម្លង **ឯកសារទី៥ខ៖** ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ
- ថតចម្លង **ឯកសារទី៦៖** វិធីសាស្ត្របង្រៀនខ្លះៗ ដែលមានប្រយោជន៍នៃការសិក្សារបែបស្ថាបនានិយម
- ថតចម្លង **ឯកសារទី៧៖** វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហាដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម

- សៀវភៅសិក្សាគោលសាលាមធ្យមសិក្សាគ្រប់មុខវិទ្យា (ដូចជា៖ គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា គណិតវិទ្យា ភាសាខ្មែរ និងសិក្សាសង្គម)
- ក្រដាសស្ទីកគ័រពណ៌ដែលមិនទាន់សរសេរ សម្រាប់ប្រើប្រាស់ជាបណ្ណការពិត (Fact card) និង បណ្ណលទ្ធផល (Consequence card) ដែលត្រូវបំពេញដោយសិក្ខាកាមតាមក្រុមពេលពិនិត្យមើលសៀវភៅសិក្សាគោល។
- រូបភាពអ៊ិតផ្លាស្ទិចរឹង ៣ ឬ៤សន្លឹកបង្ហាញពីសកម្មភាពនៅប្រទេសចិននាសម័យបុរាណដែលមានបង្ហាញនៅក្នុង **ឯកសារយោងទី៧។**
- ក្រដាសប៉ុស្ទ័រដោយមានគោលការណ៍គន្លឹះសំខាន់ៗ សរសេរលើនោះ

## លទ្ធផលសិក្សា៖

- អ្នកចូលរួមអាច**ពន្យល់**បានពីទំនាក់ទំនងរវាងការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy ចំពោះកម្រិតនៃការគិត ហើយអាចបង្កើតសំណួរផ្សេងៗ ត្រឹមត្រូវតាមកម្រិតនីមួយៗ ។
- អ្នកចូលរួមអាច**ពន្យល់**ពីជំហានសំខាន់ៗ ក្នុងការបង្កើតគំនិត និងអាច**បំពេញ**លំហាត់ដោយប្រើប្រាស់ជំហានទាំងនេះ។
- អ្នកចូលរួមអាច**បង្ហាញពីភាពខុសគ្នា**រវាងបច្ចេកទេសផ្សេងៗដែលប្រើប្រាស់សម្រាប់ការបង្កើតគំនិតរួមមាន"ផែនទីគំនិត" និង "ផែនការបញ្ញត្តិ"។
- អ្នកចូលរួមអាច**ឆ្លើយ**សំណួរដែលពាក់ព័ន្ធនឹងការវិភាគពីលំហាត់បង្កើតបញ្ញត្តិដែលអនុវត្តដោយសិស្ស។
- អ្នកចូលរួមអាច**បំពេញ**លំហាត់បាន ដោយពួកគេត្រូវប្រើប្រាស់បច្ចេកទេសបង្រៀនមួយចំនួន ដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម ជាមួយមេរៀនជាក់ស្តែងណាមួយក្នុងការបង្កើតលំហាត់ដោយអនុវត្តតាមទម្រង់ និងគោលការណ៍ដូចគ្នានេះដែរ ។
- អ្នកចូលរួមអាច**ពន្យល់**ថា លំហាត់ដែលពួកគេធ្វើតាមវិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហា គឺជាឧទាហរណ៍ជាក់ស្តែងមួយពីការអនុវត្តគោលវិធីបែបស្ថាបនានិយមនៅក្នុងការបំប៉ននេះ ។

# ផែនការមេរៀន

## លទ្ធផលសិក្សា

បិទផ្ទាំងក្រដាសលើក្តារខៀនសង្ខេបអំពីលទ្ធផលសិក្សា។ ពន្យល់អំពីលទ្ធផល និងពីអ្វីដែលសិក្ខាកាមអាចនឹងធ្វើបាននៅចុងបញ្ចប់នៃមេរៀន។

## ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy

អ្នកសម្របសម្រួលគួរចាប់ផ្តើមការពិភាក្សានេះ ដោយរំលេចពីគោលការណ៍គន្លឹះដែលសិក្សារួចមកហើយ អំពីការសិក្សាតាមបែបស្ថាបនានិយមដែលផ្តោតខ្លាំងទៅលើបំណិនគិតកម្រិតខ្ពស់ ។ ប្រសិនបើយើងភ្ជាប់គោលការណ៍នេះទៅនឹង Bloom's Taxonomy យើងនឹងសន្និដ្ឋានថាការសិក្សាតាមបែបស្ថាបនានិយមភាគច្រើនត្រូវការបំណិនគិតកម្រិតខ្ពស់ទាំង ៣ រួមមាន **ការវិភាគ វាយតម្លៃ** និង**បង្កើតថ្មី**។ ប៉ុន្តែមុននឹងផ្តល់ចម្លើយនេះ សុំសួរសិក្ខាកាមទាំងអស់ថាតើកម្រិតខ្ពស់បំផុតទាំង ៣ នៃ Bloom's Taxonomy គឺមានអ្វីខ្លះ?

បន្ទាប់មកចែក**ឯកសារទី៤**: ការផ្សាភ្ជាប់រវាងការសិក្សាតាមបែបស្ថាបនានិយម និង Bloom's Taxonomy។ រំឭកឡើងវិញនូវកម្រិតនៃការគិតតាម Taxonomy ក្នុងករណីអ្នកចូលរួមខ្លះមិនសូវច្បាស់អំពីវា ដោយចង្អុលបង្ហាញថា កម្រិតនៃការគិតនីមួយៗត្រូវការបំណិនទាំងឡាយនៅពីក្រោមវា ។ សំខាន់បំផុត កំណត់លក្ខណៈសម្គាល់ពីកម្រិតវិភាគ វាយតម្លៃ និងបង្កើតថ្មី៖

- **ការវិភាគ**៖ បែងចែកសម្ភារៈ ឬបញ្ញត្តិជាផ្នែកតូចៗ ដើម្បីធ្វើយ៉ាងណាឱ្យយល់ពីរចនាសម្ព័ន្ធរបស់វា។ បែងចែកភាពខុសគ្នារវាងការពិត (fact) និងសេចក្តីសន្និដ្ឋាន (Inference)។
- **ការវាយតម្លៃ**: ធ្វើការវាយតម្លៃនៃគំនិត តួអង្គ ហេតុការណ៍ ឬសម្ភារៈ ណាមួយ ដោយបង្កើតលក្ខណៈវិនិច្ឆ័យស្តង់ដាមួយ យកមកវាស់វែង ។
- **ការបង្កើតថ្មី**: បង្កើតរចនាសម្ព័ន្ធ ឬលំនាំពីផ្នែកតូចៗ។ ដាក់ផ្នែកតូចៗទាំងអស់ចូលគ្នា ដើម្បីបង្កើតជារចនាសម្ព័ន្ធទាំងមូល ដោយផ្តោតទៅ

លើការបង្កើតអត្ថន័យថ្មី ឬរចនាសម្ព័ន្ធថ្មីមួយ។[1]

បន្តពន្យល់ថា Bloom's taxonomy មានប្រយោជន៍ដល់ការសិក្សាតាមបែបស្ថាបនានិយមដោយវិធី ២ យ៉ាង។ **ទីមួយ** វាអាចជួយយើងក្នុងការកំណត់សកម្មភាពនៅក្នុងកម្រិតជាក់លាក់មួយ។ ឧទាហរណ៍មួយចំនួន មានផ្តល់ជូនក្នុងដ្យាក្រាមដំបូងគេក្នុង **ឯកសារចែកទី៤** ។ **ទីពីរ** វាអាចជួយយើងក្នុងការកំណត់ប្រភេទសំណួរ ដែលតម្រូវឱ្យមានបំណិនដោះស្រាយបញ្ហានៅកម្រិតខ្ពស់។

រំឭកឡើងវិញនូវឧទាហរណ៍ខ្លះៗ ពីសកម្មភាពនិងសំណួរនៅកម្រិតពុទ្ធិនីមួយៗ ដែលមានផ្តល់ជូននៅក្នុង**ឯកសារចែកទី៤** ហើយឆ្លើយសំណួរដែលសិក្ខាកាមសួរ។

នៅពេលដែលពន្យល់ចប់ សុំឱ្យសិក្ខាកាមក្នុងក្រុមបង្កើតសំណួរការសិក្សាតាមបែបស្ថាបនានិយម ដែលបង្ហាញជាគំរូកម្រិតពុទ្ធិទាំងបីនៅក្នុង Bloom's Taxonomy ដោយប្រើប្រាស់លំហាត់ដែលបានផ្តល់នៅខាងផ្នែកខាងក្រោមនៃឯកសារដែលបានចែក។ សិក្ខាកាមអាចជ្រើសរើសសំណួរពីមុខវិជ្ជាណាមួយ ដែលពួកគេគិតថាស្រួល។ ផ្តល់ពេលប្រហែល 15 នាទីសម្រាប់លំហាត់នេះ។

នៅពេលដែលក្រុមនីមួយៗបានបញ្ចប់កិច្ចការ សុំឱ្យពួកគេសរសេរសំណួរនៅលើក្តារខៀន ហើយពិភាក្សាសំណួរទាំងនោះជាក្រុម ដោយពិនិត្យមើលថាតើសំណួរទាំងនោះពិតជាបង្ហាញបំណិនស្របតាមនិយមន័យដែលបានផ្តល់ជូនដែរឬទេ?

## ការបង្កើតបញ្ញត្តិនៅក្នុងថ្នាក់សិក្សាតាមបែបស្ថាបនានិយម

ចាប់ផ្តើមមេរៀននេះ ដោយរំឭកឡើងវិញនូវចំណុចមួយចំនួនដែលបានលើកឡើងពីខាងដើម អំពីនិយមន័យរួមនៃការសិក្សាតាមបែបស្ថាបនានិយម ។ ហេតុនេះ សុំសួរសំណួរខាងក្រោមៈ

*តើផ្នែកសំខាន់ៗ ក្នុងការកំណត់និយមន័យការសិក្សាបែបស្ថាបនានិយមមានអ្វីខ្លះ?*

ចម្លើយគឺៈផ្តល់បរិបទថ្មីមួយ ដែលសិស្សអាចបង្កើតបញ្ញត្តិថ្មី ដោយប្រើទិន្នន័យដែលមានស្រាប់ ។

[1] http://www.nwlink.com/~donclark/hrd/bloom.html

ចែក**ឯកសារចែកទី៥ក៖ ការបង្កើតបញ្ញត្តិ និងការសិក្សាតាមបែបស្ថាបនានិយម** បន្ទាប់មក ដឹកនាំការពិភាក្សាជាមួយសិក្ខាកាម ដោយរំឭកឡើងវិញពីគោលការណ៍សំខាន់ដោយប្រើប្រាស់សំណួរ និងចម្លើយខាងក្រោម៖

- តើមានប៉ុន្មានជំហានក្នុងការរៀបចំដំណើរការបង្កើតបញ្ញត្តិ? (មាន ៤ ជំហានដូចមានរៀបរាប់នៅក្នុងឯកសារចែក)
- តើសិស្សត្រូវធ្វើអ្វីខ្លះដើម្បីដាក់បញ្ចូលគ្នានូវទិន្នន័យច្រើន? (ឧ. វិភាគទំនាក់ទំនងរបស់ទិន្នន័យ ធ្វើចំណាត់ថ្នាក់ទិន្នន័យទៅតាមប្រភេទ ។ល។)
- តើបំណិននៃការគិតស៊ីជម្រៅអ្វីខ្លះ ដែលអ្នកនឹកឃើញទាក់ទងនឹងការវិភាគទំនាក់ទំនង? (ឧ. សទិសភាព- ដោយរកមើលទំនាក់ទំនង ការចាត់ថ្នាក់ ។ ល។)
- តើកម្រិតនៃការគិតអ្វីខ្លះ នៅក្នុងប្លូមតាក់សូណូមី ដែលអ្នកនឹកឃើញទាក់ទងនឹងជំហាននៃការបង្កើតបញ្ញត្តិទាំងនេះ?

  (ឧ. ការវិភាគពីទំនាក់ទំនង ជា**បំណិនវិភាគ** - ការបង្កើតលក្ខណៈវិនិច្ឆ័យស្តង់ដាដើម្បីវាយតម្លៃទិន្នន័យជា**បំណិនវាយតម្លៃ**-ការបញ្ចូលនូវទិន្នន័យជាច្រើនដើម្បីបង្កើតបញ្ញត្តិថ្មី ជា**បំណិននៃការបង្កើតថ្មី** ។ល។)
- នៅពេលដែលសិស្សចែករំលែកនូវសម្មតិកម្មដែលគេរកឃើញ តើសកម្មភាពនេះឆ្លុះបញ្ចាំងអំពីគោលការណ៍អ្វីនៃការសិក្សាតាមបែបស្ថាបនានិយម?

  (ឧ. ការសិក្សាបែបសហការ)
- តើវិធីសាស្ត្របង្រៀនអ្វីផ្សេងទៀតត្រូវបានអនុវត្តនៅក្នុងដំណើរការនេះ?

  (ឧ. ការសិក្សាបែបសហការ)

នៅពេលអ្នកសម្របសម្រួលបញ្ចប់ការរំឭកពីជំហានក្នុងការបង្កើតបញ្ញត្តិ គាត់ត្រូវឆ្លងទៅពិភាក្សាពីមធ្យោបាយផ្សេងៗដែលប្រើប្រាស់ដើម្បីបង្កើតបញ្ញត្តិ (ឧ.ផែនទីគំនិត ផែនទីបញ្ញត្តិ។ល។) ព្រមទាំងពិភាក្សាអំពីប្រយោជន៍ក្នុងការបង្កើតបញ្ញត្តិផង។ *ត្រូវចងចាំថា ការប្រើប្រាស់ដ្យាក្រាម និងរូបភាពជាឧបករណ៍ល្អបំផុតសម្រាប់សកម្មភាពនានាក្នុងការបង្កើតបញ្ញត្តិ។*

សួរសិក្ខាកាម ថាតើពួកគេធ្លាប់បានឮអំពីបច្ចេកទេសទាំងនេះពីមុនមកទេ? ធ្វើបំណកស្រាយក្នុងករណីចាំបាច់ ឧទាហរណ៍៖

| | |
|---|---|
| | - **ផែនទីគំនិត៖** ជាបច្ចេកទេសក្រាហ្វិកសម្រាប់បង្កើតផែនទី និងរៀបចំបញ្ញត្តិ ដែលប្រើមែកធាងផ្ដុំរូបខុសៗគ្នាទាំងពណ៌ និងទម្រង់។ ផែនទីគំនិតប្រើពាក្យគន្លឹះ ដើម្បីពង្រីកបានគំនិតថ្មីៗ បន្ថែមជាច្រើនទៀត។  <br>- **ផែនទីបញ្ញត្តិ៖** ជាបច្ចេកទេសក្រាហ្វិកមួយបែបទៀត ដែលស្រដៀងគ្នាទៅនឹងផែនទីគំនិតដែរ ប៉ុន្តែមានរចនាសម្ព័ន្ធ និងសេចក្ដីលម្អិតច្រើនជាង ហើយប្រើប្រាស់ឃ្លាប្រយោគ ឬសញ្ញាព្រួញ ដើម្បីបង្ហាញពីលំហូរ និងទិសដៅនៃគំនិត ។ល។ |
| | បន្ទាប់ពីការពន្យល់ចប់ សូមឱ្យសិក្ខាកាមធ្វើការជាក្រុម ដើម្បីបំពេញលំហាត់បង្កើតបញ្ញត្តិដែលមានផ្ដល់ជូននៅចុងបញ្ចប់ឯកសារចែកទី៥ក។ ទុកពេលប្រហែល ១៥ នាទីសម្រាប់ធ្វើលំហាត់នេះហើយលើកទឹកចិត្តសិក្ខាកាមឱ្យធ្វើការផ្ទៀងផ្ទាត់ការពិតជាមួយទិន្នន័យពីប្រព័ន្ធអ៊ីនធឺណិត ដើម្បីបន្ថែមសេចក្ដីលម្អិតទៅលើផែនទីគំនិតរបស់ពួកគេ។ |
| | អ្នកសម្របសម្រួលត្រូវរំឭកឡើងវិញនូវផែនទីគំនិត/បញ្ញត្តិ ជាក្រុមធំមួយដើម្បីធ្វើការប្រៀបធៀបភាពខុសគ្នាដែលអាចកើតមានរបស់ក្រុមនីមួយៗយល់ឃើញទៅលើទិន្នន័យ។ អ្នកសម្របសម្រួលគួរកត់សម្គាល់ថា ក្នុងការបង្កើតព័ត៌មាន គ្មានវិធីណាដែលត្រូវបានចាត់ទុកថា ត្រឹមត្រូវ ឬខុស នោះទេ ហើយភាពខុសគ្នាសុទ្ធតែអាចទទួលយកបាន ឱ្យតែការធ្វើចំណាត់ថ្នាក់ទាំងនេះតាមរបៀបមួយដែលត្រឹមត្រូវ។ |
| | បន្ទាប់មកចែក **ឯកសារចែកទី៥ខ៖ ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ** |
| | ចូរសម្គាល់ថាដ្យាក្រាមដែលបានបង្ហាញក្នុងឯកសារចែកនេះគឺជា**ផែនទីបញ្ញត្តិ។** អ្នកសម្របសម្រួលគួរពន្យល់ថាឯកសារចែកនេះបានផ្ដល់នូវឧទាហរណ៍មួយទៀតអំពីការបង្កើតបញ្ញត្តិ នៅក្នុងមុខវិជ្ជាមួយគឺប្រវត្តិវិទ្យា។ អានឯកសារចែក ដោយកត់សម្គាល់ថា លំហាត់អំពី "ហេតុនិងផល" គឺជាដំណើរការបង្កើតបញ្ញត្តិមួយទៀតដែលមានប្រយោជន៍យ៉ាងច្រើន។ |

សួរទៅសិក្ខាកាមថាតើដ្យាក្រាមដែលបានបង្ហាញគឺជាផែនទីគំនិតឬផែនទីបញ្ញត្តិ? បើពួកគេឆ្លើយថាជាផែនទីបញ្ញត្តិ សួរពួកគេថាហេតុអ្វីបានជាពួកគេគិតដូច្នេះ? ចម្លើយដែលអាចឆ្លើយ គួរតែមានដូចខាងក្រោម៖

- ដ្យាក្រាមមានរចនាសម្ព័ន្ធច្រើនជាង
- ដ្យាក្រាមមានប្រើឃ្លា និងល្បះ មិនមែនប្រើតែពាក្យគន្លឹះមួយដូចក្នុងផែនទីគំនិតទេ។
- ដ្យាក្រាមបង្ហាញប្រាប់ពីទិសដៅ

វិលត្រឡប់ទៅវិញនូវសំណួរ ដើម្បីធ្វើការពិភាក្សាជាក្រុមធំ ឬជាក្រុមតូច ប្រសិនបើមានពេល។ នៅក្នុងការពិភាក្សាបន្តបន្ទាប់ ត្រូវកត់សម្គាល់ចំណុចដូចខាងក្រោម៖

- ដ្យាក្រាមទាំងពីរត្រឹមត្រូវដូចគ្នា ប៉ុន្តែក្រុមមួយបានបង្កើតផែនទីដែលមានបញ្ញត្តិច្រើនជាង
- ដ្យាក្រាមទាំងពីរសមហេតុផលដូចគ្នា ប៉ុន្តែក្រុមមួយបានបញ្ជាក់ពីមូលហេតុដោយប្រើពណ៌ផ្សេងៗពីគ្នា

**យុទ្ធសាស្ត្របង្រៀនផ្សេងៗ ដែលមានប្រយោជន៍ក្នុងការអនុវត្តវិធីសាស្ត្រ ការសិក្សាតាមបែបស្ថាបនានិយម៖ ការសិក្សាតាមបែបសហការ**

ចាប់ផ្តើមមេរៀននេះ ដោយត្រឡប់ចូលទៅគំនិតដែលបានលើកឡើងពីខាងដើមថា ការសិក្សាតាមបែបស្ថាបនានិយម គឺពិតជាទ្រឹស្តីសិក្សាមួយដែលប្រើប្រាស់វិធីសាស្ត្រផ្សេងៗជាច្រើន ដូចជា **ការសិក្សាបែបសហការ** និង**ការសិក្សាអាស្រ័យទៅលើបញ្ហា**។ សម្រាប់មេរៀននេះ យើងសូមលើកយកគោលការណ៍មួយចំនួនពីទ្រឹស្តីសិក្សាទាំងនេះមកប្រើប្រាស់ ដើម្បីលើកកម្ពស់ការសិក្សាតាមបែបស្ថាបនានិយម។

ចែក**ឯកសារចែកទី៦៖** វិធីសាស្ត្របង្រៀនមានប្រយោជន៍មួយចំនួនសម្រាប់ប្រើក្នុងការសិក្សាតាមបែបស្ថាបនានិយម។

វិលត្រឡប់ទៅវិញនូវ*គោលការណ៍ណែនាំទូទៅ* ក្នុងឯកសារចែក អំពីវិធីសាស្ត្របង្រៀនមួយចំនួនដែលមានលក្ខណៈ "ការសហការ" រួមមាន (ក) របៀបបង្កើតក្រុម (ខ) កិច្ចការដែលគួរធ្វើក្នុងក្រុម (គ) របៀបបង្កើតសម្ភារសិក្សា ដែលជួយបញ្ជាក់ពីការយល់ដឹង និងបច្ចេកទេសផ្សេងៗទៀត។

| | |
|---|---|
| | បន្ទាប់មក អ្នកសម្របសម្រួលត្រូវពន្យល់អ្នកចូលរួមថា យើងមាន*លំហាត់ពង្រឹងពុទ្ធិ*ចំនួន២ ដែលបង្ហាញពីគំរូគោលការណ៍សិក្សាតាមបែបសហការ និងតាមបែបស្ថាបនានិយម។ លំហាត់ទីមួយឈ្មោះថា **ការសម្រេចចិត្ត-ការសម្រេចចិត្ត** (Decisions-Decisions) ហើយលំហាត់មួយទៀតឈ្មោះថា **ជីក-ស** (Jigsaw)។ ពន្យល់អំពីរបៀបលេងដោយផ្អែកលើការរៀបរាប់ក្នុងឯកសារចែក។ ធ្វើការជាក្រុមធំ មើលលំហាត់គំរូដែលបានផ្តល់ជូន ដោយឆ្លើយសំណួរដែលបានផ្តល់ ជាឧទាហរណ៍។ |
| | បន្ទាប់មក ចែកសៀវភៅសិក្សាគោល តាមឯកទេសមុខវិជ្ជា របស់សិក្ខាកាម (គីមីវិទ្យា ជីវវិទ្យា គណិតវិទ្យា ប្រវត្តិវិទ្យា ។ល។) ហើយសុំឱ្យពួកគេជ្រើសរើសមេរៀនដែលអាចបង្កើតលំហាត់បាន ដោយប្រើបច្ចេកទេសមួយក្នុងចំណោមបច្ចេកទេសទាំងពីរដែលបានស្នើខាងលើ (ឧទាហរណ៍៖ សម្រេចចិត្ត-សម្រេចចិត្ត ឬជីក-ស)។ ចំណុចនេះមានពន្យល់នៅក្នុងលំហាត់ នៅចុងបញ្ចប់ **ឯកសារចែកទី៦** ផងដែរ។ ត្រូវផ្តល់ឱ្យសិក្ខាកាមនូវក្រដាសបណ្ណស្ទីកគ័រពណ៌មិនទាន់សរសេរ (ប្រសិនបើពួកគេសម្រេចចិត្តប្រើវិធី **ការសម្រេចចិត្ត-ការសម្រេចចិត្ត** ឬឱ្យផ្ទាំងក្រដាសធំ បើពួកគេសម្រេចចិត្តប្រើវិធី **ជីក-ស**។ ផ្តល់ពេលប្រហែល ៤០នាទី សម្រាប់ក្រុមនីមួយៗធ្វើលំហាត់ និង២០ នាទីសម្រាប់ធ្វើបទបង្ហាញពីអ្វីដែលគេបានធ្វើ។ សិក្ខាកាមអាចប្រើទម្រង់គំរូដែលមានផ្តល់ជូនក្នុងឯកសារចែក ឬប្រើប្រាស់ទម្រង់ផ្ទាល់ខ្លួន។ |
| | ពិភាក្សា និងឱ្យយោបល់ទៅលើលំហាត់ដែលក្រុមនីមួយៗបានបង្កើត។ |
| | អ្នកសម្របសម្រួលត្រូវត្រួតពិនិត្យមើលថាតើលំហាត់ទាំងនេះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យខាងក្រោមដែរឬទេ៖<br>- យកគំរូតាមលំនាំដែលបានពន្យល់សម្រាប់សកម្មភាពនីមួយៗ<br>- មានសំណួរ ឬលំហាត់ នៅកម្រិតនៃការវិភាគ ការវាយតម្លៃ និងបង្កើតថ្មី<br>- សេចក្តីណែនាំសម្រាប់សិស្សច្បាស់លាស់<br>- ។ល។ |

| | |
|---|---|
| | **យុទ្ធសាស្ត្របង្រៀនផ្សេងៗ ដែលមានប្រយោជន៍ក្នុងការអនុវត្តវិធីសាស្ត្រ ការសិក្សាតាមបែបស្ពានិយម៖ ការសិក្សាអាស្រ័យលើបញ្ហា** |

មេរៀនបន្ទាប់ទៀតនេះ ផ្តោតលើការអនុវត្តវិធីសាស្ត្រ**ការសិក្សាអាស្រ័យលើបញ្ហា** ទៅនឹងការសិក្សាតាមបែបស្ពានិយម។ អ្នកសម្របសម្រួល គួរតែពន្យល់ថាការសិក្សាតាមបែបស្ពានិយមអាចខ្ចីគោលការណ៍ជាច្រើនពី**ការសិក្សាអាស្រ័យលើបញ្ហា** ដែលនាំទៅរកការបង្កើតបញ្ញត្តិ និងបំណិនផ្សេងៗ។ សរសេរគោលការណ៍គន្លឹះខាងក្រោម ដែលបង្ហាញពី**ការសិក្សាអាស្រ័យលើបញ្ហា** នៅលើក្តារខៀន៖

(ក) កំណត់ពីអ្វីមួយដែលបានដឹងរួចហើយ

(ខ) កំណត់ពីអ្វីមួយដែលត្រូវដឹង និង

(គ) ដឹងពីរបៀប និងកន្លែង ដែលត្រូវរកព័ត៌មានដើម្បីដោះស្រាយបញ្ហា

បន្តពន្យល់ថា ពេលដែលយើងដោះស្រាយបញ្ហា យើងត្រូវ **វិភាគបរិបទ** និងចំណេះដឹងផ្ទាល់ខ្លួនដែលមានស្រាប់ កំណត់ពីអ្វីដែលខ្លួនត្រូវដឹង (**វាយតម្លៃ**) និងបង្កើតដំណោះស្រាយ (**ការបង្កើតថ្មី**) ។

បង្ហាញ ឧទាហរណ៍ ដោយចែករូបភាពចិនបុរាណដែលបានអ៊ុតផ្តាស្ទិចរួច។

ពន្យល់ថារូបភាពជីវភាពចិនបុរាណមានកំហុស(បញ្ហា)ខ្លះទាក់ទងនឹងប្រវត្តិសាស្ត្រ។ សិស្សត្រូវស្វែងរកកំហុសប្រវត្តិសាស្ត្រនៅក្នុងរូបភាព ហើយពន្យល់ថាហេតុអ្វីបានជាខុស(ដំណោះស្រាយ)។



ឱ្យសិក្ខាកាមស្វែងរកកំហុសនៅក្នុងរូបភាពប្រហែល ១៥ នាទី បន្ទាប់មកពន្យល់ថាហេតុអ្វីបានជាខុស? ប្រើកុំព្យូទ័រយួរដៃ ឬកុំព្យូទ័របន្ទះស្មើង ដើម្បីស្រាវជ្រាវតាមអ៊ីនធឺណិតស្វែងរកការវិភាគរបស់អ្នក។

ប្រើប្រាស់តារាងគំរូខាងក្រោមដើម្បីដោះស្រាយបញ្ហាដែលបានផ្ដល់ជូន។

| កំហុសក្នុងរូបភាព | ការពន្យល់ |
|---|---|
| ១. **ឧទាហរណ៍៖** ចិនបុរាណមិនមានរទេះរុញសម័យទំនើបទេ | ទោះបីចិនបង្កើតឧបករណ៍រទេះរុញមុនគេដែលគេហៅថា "គោឈើ" ដូចមានបង្ហាញនៅក្នុងរូបភាពនេះក៏ដោយក៏ពួកគេមិនមានឧបករណ៍គោឈើលក្ខណៈទំនើប ដូចក្នុងរូបដែរ។ គោឈើមានកង់នៅកណ្ដាល ចំណែករទេះរុញសម័យទំនើបមានទីប្រជុំទម្ងន់ខិតជិតទៅខាងចុងរទេះជាង។ |
| ២. | |
| ៣. | |
| ៤. | |
| ៥. | |
| ៦. | |
| ៧. | |

នៅពេលសិក្ខាកាមបានបំពេញលំហាត់រួចហើយ សួររកចម្លើយយ៉ាងលឿនពីគ្រប់គ្នាដោយរំឭកឡើងវិញនូវការពន្យល់ដែលបានផ្ដល់ជូនក្នុង**ឯកសារចែកទី៧**។

បន្ទាប់មក អ្នកសម្របសម្រួលគួរឱ្យសិក្ខាកាមរំឭកឡើងវិញនូវសំណួរពិភាក្សាក្នុងឯកសារចែកទី៧ និងបំផុសប្រមូលគំនិតរកចម្លើយមួយចំនួនដើម្បីឆ្លើយទៅនឹងសំណួរនីមួយៗ។ នៅពេលប្រមូលបានចម្លើយហើយ ព្យាយាមធ្វើបញ្ជីចម្លើយនៅលើក្ដារខៀនជាក្រុមធំ។ ប្រើសំណួរខាងក្រោម ដើម្បីជួយដឹកនាំការពិភាក្សា៖

*១. តើអ្នកអាចរកឃើញកំហុសបានប៉ុន្មាន?*

- មាន ៧ កំហុសនៅក្នុងរូបភាពនេះ ហើយយើងបានរកឃើញទាំងអស់។

| | |
|---|---|
| | *២. តើក្រុមរបស់អ្នកដឹងអ្វីខ្លះអំពីកំហុសក្នុងរូបភាព? (ឧទាហរណ៍៖ កាលបរិច្ឆេទដែលមហាកំផែងត្រូវបានកសាង បច្ចេកវិទ្យាដែលមាននៅសម័យនោះ ។ល។)។*<br>- យើងបានដឹងហើយថា រូបភាពនេះ ត្រូវបានកំណត់នៅសម័យកាលនៃការកសាងមហាកំផែងចិន<br>- មហាកំផែងចិន ត្រូវបានកសាងនៅប្រហែល ២០០ ឆ្នាំមុនគ្រឹះសករាជ ដែលឆ្លងកាត់ជាច្រើនសតវត្សរ៍មកហើយ<br>- បច្ចេកវិទ្យាពេលនោះគឺមានតិចតួច និងទំនាក់ទំនងជាមួយអឺរ៉ុបគឺលំបាក<br>*៣. តើអ្នកបានកំណត់អ្វីដែលអ្នកត្រូវដឹង ដើម្បីដោះស្រាយបញ្ហាដោយរបៀបណា? (ឧទាហរណ៍៖ តើវត្ថុអ្វីដែលអ្នកដឹងមិនប្រាកដក្នុងរូបភាពដែលអ្នកសង្កេត?)*<br>- យើងត្រូវដឹងថាពេលណារទេះរុញសម័យទំនើបត្រូវបានបង្កើតឡើង<br>- យើងត្រូវដឹងថាពេលណាប៉មទួរអេវហ្វែល (Eiffel Tower) ត្រូវបានកសាង<br>- យើងត្រូវដឹងថាលុយចិនបុរាណមានសណ្ឋានដូចម្តេច?<br>- យើងត្រូវដឹងថាពេលណាផ្លូវដែកត្រូវបានចាប់ផ្តើមប្រើប្រាស់<br>- យើងត្រូវដឹងថាពេលណាប្រទេសអង់គ្លេសក្លាយជាប្រទេសមួយដែលយកនិមិត្តសញ្ញាព្រះយេស៊ូ ដាក់នៅលើទង់ជាតិ<br>- ។ល។<br>*៤. តើអ្នកអាចកំណត់អ្វីដែលអ្នកមិនទាន់បានដឹង ដើម្បីដោះស្រាយបញ្ហាយ៉ាងងាយតាមវិធីណា?*<br>- ស្វែងរកតាម Google ក្នុងប្រព័ន្ធអ៊ីនធឺណែត |

# មេរៀន ៣.៣៖ ការបង្កើតបរិបទស្ថាប័នដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម

**រយៈពេលបង្រៀន៖ ៩០នាទី**

**ការត្រៀមលក្ខណៈ**

- សរសេរលទ្ធផលសិក្សានៅលើផ្ទាំងក្រដាសធំដើម្បីបង្ហាញមេរៀន
- ថតចម្លង**ឯកសារចែកទី៨៖** *ដំណើរការ និង ផលិតផល នៃការសិក្សាតាមបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារចែកទី៩**: *ការសិក្សាតាមបែបស្ថាបនានិយម និងបច្ចេកវិទ្យា*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ផ្ទាំងក្រដាស ហ្វីត
- ផ្ទាំងក្រដាសសង្ខេបអំពីលទ្ធផលសិក្សា
- **ឯកសារចែកទី៨៖** *ដំណើរការ និងផលិតផល នៃការសិក្សាតាមបែបស្ថាបនានិយម*
- **ឯកសារចែកទី៩៖** *ការសិក្សាតាមបែបស្ថាបនានិយម និងបច្ចេកវិទ្យា*

**លទ្ធផលសិក្សា**

- សិក្ខាកាមអាច**កំណត់**បច្ចេកទេសបង្រៀនជាក់លាក់ (ឧ. ការងារក្រុម ការងារពិសោធន៍ ទស្សនកិច្ចសិក្សា ។ ល។) ដែលបង្ហាញជាគំរូអំពីការសិក្សាតាមបែបស្ថាបនានិយម។
- សិក្ខាកាមអាច**កំណត់**ថាតើសកម្មភាពសិក្សាតាមបែបស្ថាបនានិយម ទាំងនេះជាដំណើរការ ឬជាផលិតផល?
- សិក្ខាកាមអាច**កំណត់**ពីបច្ចេកទេសបង្រៀនជាក់លាក់ ដែលជាគំរូពីគោលការណ៍គន្លឹះនៃការសិក្សាតាមបែបស្ថាបនានិយម ។
- សិក្ខាកាមអាច**កំណត់**លក្ខខណ្ឌចាំបាច់របស់ស្ថាប័ន ដើម្បីអនុវត្តបច្ចេកទេសបង្រៀនដែលជំរុញការសិក្សាតាមបែបស្ថាបនានិយម។

# ផែនការបង្រៀន

## លទ្ធផលសិក្សា

បិតផ្ទាំងក្រដាសលើក្ដារខៀនដែលសង្ខេបពីលទ្ធផលសិក្សា។ ពន្យល់ពីលទ្ធផល និងប្រាប់ថានេះគឺជាអ្វីដែលសិក្ខាកាមគួរតែចេះនៅពេលបញ្ចប់មេរៀន។

## ដំណើរការ និងផលិតផល នៃការសិក្សាតាមបែបស្ថាបនានិយម

អ្នកសម្របសម្រួលគួរចាប់ផ្ដើមមេរៀននេះដោយពន្យល់ថាការសិក្សាតាមបែបស្ថាបនានិយមលើកកម្ពស់ការបង្កើត ដំណើរការសិក្សា និងផលិតផលសិក្សា។ លទ្ធផលដែលកើតចេញមានច្រើនទម្រង់។

ព្យាយាមបំផុសគំនិតជាមួយសិក្ខាកាម ដោយសរសេរបញ្ជីនៅលើក្ដារខៀន។ រំឭកសិក្ខាកាមថាសកម្មភាពទាំងនេះ គួរតែបង្ហាញពីបំណិនគិតកម្រិតខ្ពស់ ។ ផ្ដល់នូវឧទាហរណ៍មួយចំនួន ដូចជាការធ្វើបទបង្ហាញ ការតាំងពិព័រណ៍ ។ល។ ដើម្បីឱ្យសិក្ខាកាមយល់គំនិតមួយចំនួនអំពីប្រភេទសកម្មភាពដែលពួកគេគួរតែបំផុសគំនិត។

បន្ទាប់មក ចែក**ឯកសារចែកទី៨៖** ដំណើរការ និង ផលិតផល នៃការសិក្សាតាមបែបស្ថាបនានិយម។ ប្រៀបធៀបបញ្ជីលើក្ដារខៀនជាមួយបញ្ជីនៅក្នុងឯកសារចែក។ ពិភាក្សាថាតើមានសកម្មភាពណាមួយដែលមិនពាក់ព័ន្ធ? សកម្មភាពដែលគួរបន្ថែម ។ល។ រំឭកឡើងវិញថាសកម្មភាពទាំងនោះ មាននៅក្នុងឯកសារចែក ជាពិសេសសកម្មភាពដែលមិនបានបង្ហាញនៅក្នុងបញ្ជីបំផុសគំនិត។

បន្ទាប់ពីពិភាក្សារួច សូមឱ្យសិក្ខាកាមជ្រើសយកសកម្មភាពមួយចេញពីបញ្ជី ហើយធ្វើលំហាត់ដែលមាននៅក្នុង **ឯកសារចែកទី៨**។ ក្រុមនីមួយៗត្រូវជ្រើសយកសកម្មភាព "មួយ" ប៉ុណ្ណោះ។ ផ្ដល់ឱ្យក្រុមប្រហែល ១០ ទៅ ១២ នាទីសម្រាប់សកម្មភាពនេះ។ នៅពេលពួកគេធ្វើសកម្មភាពរួច ដឹកនាំការពិភាក្សាអំពីចម្លើយបានមកពីក្រុមនីមួយៗ។ ឧទាហរណ៍មួយចំនួនត្រូវបានផ្ដល់ជូនសម្រាប់អ្នកសម្របសម្រួលដើម្បីជួយដឹកនាំការពិភាក្សា និងពិនិត្យចម្លើយ។

| សកម្មភាពសិក្សាតាមបែបស្ថាបនានិយម | ផលិតផល ឬដំណើរការ | របៀបដែលទាក់ទងនឹងគោលការណ៍ការសិក្សាបែបស្ថាបនានិយម |
|---|---|---|
| គម្រោងវិទ្យាសាស្ត្រ (ឧទាហរណ៍) | ✚ ដំណើរការ (លុះត្រាតែមានលទ្ធផលជាក់ស្តែង ដូចជាកូនសៀវ ភៅ គំរូគម្រោង។ល។) | ✚ មានអន្តរកម្ម ពីព្រោះសិស្សធ្វើការងារជាក្រុម<br>✚ ការសិក្សាបែបសម្របសម្រួល ពីព្រោះសិស្សអាចរៀននៅក្នុងបរិបទមិនមានរចនាសម្ព័ន្ធដែលអាចឱ្យពួកគេ អាចសួរសំណួរក្នុងក្រុម និងជាមួយគ្រូបានដោយសេរី<br>✚ មានភាពជាក់ស្តែង ប្រសិនបើដោះស្រាយបញ្ហាជីវិតជាក់ស្តែង ដូចជាការបំពុលទឹក គ្រោះថ្នាក់នៃការលាយកូកាកូឡាជាមួយម៉ង់តូស បញ្ហាតមអាហារ ។ល។<br>✚ សិស្សមជ្ឈមណ្ឌល ពីព្រោះវាអាចឱ្យសិស្សកំណត់ព្រំដែននៃអ្វីដែលពួកគេធ្វើសម្រាប់គម្រោង និងរបៀបដែលពួកគេធ្វើ<br>✚ ពាក់ព័ន្ធការគិតកម្រិតខ្ពស់ ពីព្រោះសិស្សត្រូវវិភាគបញ្ហាប្រធានបទវិទ្យាសាស្ត្រ និងធ្វើសេចក្តីសន្និដ្ឋាន (វាយតម្លៃ) |
| គម្រោងដែលធ្វើជាក្រុម | ✚ ដំណើរការ និងផលិតផល | ✚ |
| ការតាំងពិព័រណ៍ | ✚ ផលិតផល | ✚ |
| បទបង្ហាញ | ✚ ដំណើរការ | ✚ |
| សៀវភៅរបាយការណ៍និងសៀវភៅកំណាព្យ | ✚ ផលិតផល | ✚ |
| ស្រាវជ្រាវតាមអ៊ីនធឺណេត | ✚ ដំណើរការ | ✚ |
| ទស្សនកិច្ចសិក្សា | ✚ ដំណើការ | ✚ |
| ការងារពិសោធន៍វិទ្យាសាស្ត្រ | ✚ ដំណើរការ<br>✚ ផលិតផល | ✚ |

បន្ទាប់មក អ្នកសម្របសម្រួលពន្យល់ថា ការរៀបចំសកម្មភាពសិក្សាតាមបែបស្ថាបនានិយម នៅក្នុងសាលារៀន និងថ្នាក់រៀន អាចជាបញ្ហាប្រឈមមួយ ប្រសិនបើមិនមានការរៀបចំបរិស្ថានសិក្សាសម្រាប់ការអនុវត្តគោលវិធីនេះដោយប្រសិទ្ធិភាព។

ឧទាហរណ៍ ចូរពិចារណាសំណួរមួយចំនួនដូចខាងក្រោម៖

- តើសាលារៀនមានក្លឹបសិក្សាមុខវិជ្ជាដែលជាសកម្មភាពសិក្សាក្រៅថ្នាក់ដូចជាមុខវិជ្ជា វិទ្យាសាស្ត្រ ប្រវិត្តិវិទ្យា និងគម្រោងដទៃទៀតដែរឬទេ?
- តើក្លឹបសិក្សាមុខវិជ្ជាមានថវិកាទេ?
- តើសាលារៀនមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ដែលការងារពិសោធន៍អាចត្រូវបានអនុវត្តដែរឬទេ? តើបន្ទប់ពិសោធន៍មានសម្ភារៈដែរឬទេ?
- តើថ្នាក់រៀន មានក្តារព័ត៌មាន ឬទូ សម្រាប់តាំងពិព័រណ៍ដែរឬទេ?
- តើសាលារៀនមានការរៀបចំទស្សនកិច្ចសិក្សា ដែលមាតាបិតាសិស្សត្រូវចុះហត្ថលេខាលើទម្រង់អនុញ្ញាតឱ្យបុត្រធីតា បានចូលរួម ។ល។ ដែរឬទេ?

គូសតារាងនៅចុង**ឯកសារចែកទី៨** (ទំព័រ ២) នៅលើក្តារខៀន ហើយបំពេញតារាងជាក្រុមធំ ដោយកំណត់តម្រូវការស្ថាប័ន ឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីសម្រួលការអនុវត្តសកម្មភាពនីមួយៗប្រកបដោយជោគជ័យ។

| សកម្មភាពសិក្សាតាមបែបស្ថាបនានិយម | តម្រូវការស្ថាប័ន |
|---|---|
| **គម្រោងវិទ្យាសាស្ត្រ** | ✚ ការរៀបចំសម្រាប់គ្រូវិទ្យាសាស្ត្រម្នាក់ដែលស្ម័គ្រចិត្តផ្តល់ប្រឹក្សាដល់ក្លឹបមុខវិជ្ជាវិទ្យាសាស្ត្រ<br>✚ ថវិកាសម្រាប់សម្ភារៈ<br>✚ ពេលវេលាគ្រប់គ្រាន់៖ សកម្មភាពក្រៅថ្នាក់ ឬម៉ោងបន្ថែម<br>✚ សៀវភៅចំប៉ិនក្លឹបមុខវិជ្ជា |
| **គម្រោងដែលធ្វើជាក្រុម** | ✚ ការរៀបចំកន្លែងអង្គុយសមរម្យក្នុងថ្នាក់រៀនសម្រាប់ការងារក្រុម<br>✚ សម្ភារៈសម្រាប់ស្រាវជ្រាវតាមអ៊ីនធឺណែត<br>✚ ពេលវេលាគ្រប់គ្រាន់សម្រាប់សកម្មភាពក្រៅថ្នាក់ ឬម៉ោងបន្ថែម<br>✚ សម្ភារៈការិយាល័យ សម្រាប់សិក្សា របាយការណ៍ ។ល។ |
| **ការតាំងពិព័រណ៍** | ✚ ក្តារព័ត៌មាននៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់សម្រាប់តាំងពិព័រណ៍<br>✚ ក្តារខៀនព័ត៌មាន និងទូតាំង<br>✚ ថវិកាសម្រាប់សម្ភារៈចាំបាច់ |

| | |
|---|---|
| | ✚ ការរៀបចំពិធីពិពរណ៌ រាត្រីឬទិវាជួបជុំអាណាព្យាបាល<br>✚ សម្ភារៈស្រាវជ្រាវតាម អ៊ីនធឺណែត និងបោះពុម្ព |
| **បទបង្ហាញ** | ✚ ការប្រើប្រាស់ ម៉ាស៊ីន LCD<br>✚ ពេលវេលា ក្នុងកាលវិភាគបង្រៀន (ឧ. នៅក្រោមរបបសាលារៀនជំនាន់ថ្មី) ឬពេលវេលាសកម្មភាពក្រៅថ្នាក់<br>✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ ការប្រើសុសវែរ ដើម្បីធ្វើបទបង្ហាញ ដូចជាកម្មវិធី PowerPoint |
| **សៀវភៅរបាយការណ៍ និងកំណាព្យ** | ✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ មានក្លឹបសិក្សា<br>✚ សម្ភារៈបោះពុម្ព និងថវិកាគាំទ្រ |
| **ការស្រាវជ្រាវតាមអ៊ីនធឺណែត** | ✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ មានសេវាអ៊ីនធឺណែត |
| **ទស្សនកិច្ចសិក្សា** | ✚ ពិធីសារជាលាយលក្ខណ៍អក្សរសម្រាប់ការរៀបចំសិស្ស (ឧ. ចំនួនសិស្សដែលត្រូវគ្រប់គ្រងដោយគ្រូម្នាក់ ទម្រង់សុំការអនុញ្ញាតពីមាតាបិតាសិស្ស ។ល។)<br>✚ ថវិកាសម្រាប់ការធ្វើដំណើរ តម្លៃចូលរួម ។ល។ |
| **ការងារពិសោធវិទ្យាសាស្ត្រ** | ✚ ការចូលប្រើសម្ភារៈពិសោធន៍វិទ្យាសាស្ត្រ<br>✚ ការអាចរកបាននូវសម្ភារៈពិសោធន៍<br>✚ ពេលវេលា ក្នុងកាលវិភាគបង្រៀន(ឧ. នៅក្រោមរបបសាលារៀនជំនាន់ថ្មី) ឬពេលវេលាសកម្មភាពក្រៅថ្នាក់ |

## ការសិក្សាតាមបែបស្ថាបនានិយម និងបច្ចេកវិទ្យា

ចាប់ផ្តើមមេរៀនចុងក្រោយនេះ ដោយពន្យល់ថាបច្ចេកវិទ្យាគឺជាឧបករណ៍ល្អបំផុតសម្រាប់ជួយសម្រួលដល់ការផលិត ផលិតផលសិក្សា ដូចជារបាយការណ៍ បទបង្ហាញតាម PowerPoint សៀវភៅកំណាព្យ។ល។ ការចងបណ្តាញសិក្សា និងការចែករំលែក ផ្តល់ឱកាសដល់សិស្សក្នុងការសហការគ្នា ចែករំលែកគំនិតគ្នា ។ល។ ដូចនេះ ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសាលារៀនមួយគឺ ជាតម្រូវការស្ថាប័នសំខាន់ដែលអាចជួយសម្រួលដល់ការសិក្សាតាមបែបស្ថាបនានិយម។

សង្ខេបគំនិតនេះដោយគូសដ្យាក្រាមខាងក្រោមនៅលើក្ដារខៀន៖




ចែក**ឯកសារទី៩៖ ការសិក្សាតាមបែបស្ថាបនានិយម និងបច្ចេកវិទ្យា**

រំឭកឡើងវិញនូវវិធីមួយចំនួនដែលបច្ចេកវិទ្យាអាចលើកកម្ពស់ការផលិត ផលិតផលសិក្សា និងការសហការ។ សរសេរវិធីទាំងនេះនៅក្រោមប្រអប់ដ្យាក្រាមទាំងពីរ ដែលអ្នកបានគូសនៅលើក្ដារខៀន ដោយយោងតាមអ្វីដែលវិធីទាំងនោះជំរុញខ្លាំងបំផុត។ ឧទាហរណ៍ ឧបករណ៍ទូរគមនាគមន៍បានលើកកម្ពស់យ៉ាងច្បាស់ដល់ការសហការ និងការទំនាក់ទំនង។

- *ឧបករណ៍ទូរគមនាគមន៍* ដូចជាអ៊ីម៉ែលនិងអ៊ីនធឺណែត ផ្ដល់នូវមធ្យោបាយសម្រាប់ការសន្ទនា ពិភាក្សា និងជជែកដេញដោលជាដើម ដែលជាអន្តរកម្មនាំទៅរកការបង្កើតអត្ថន័យសង្គម។
- *បទបង្ហាញជា PowerPoint៖* បទបង្ហាញដែលបង្កើតឡើងដោយសិស្សនៅក្នុងក្រុមរបស់ពួកគេក៏បានផ្ដល់នូវបណ្ដាញសង្គមដ៏មានប្រយោជន៍សម្រាប់សិស្សធ្វើការរួមគ្នាជាក្រុម ក្នុងការផលិតជាផលិតផលសិក្សាប្រកបដោយការច្នៃប្រឌិតដើម្បីចែករំលែកជាមួយសិស្សក្នុងថ្នាក់។ សាលាគួរតែមានម៉ាស៊ីន LCD សម្រាប់បញ្ចាំង ហើយដែលទាំងគ្រូនិងសិស្សអាចប្រើប្រាស់បានសម្រាប់គោលបំណងនេះ។
- *សម្ភារៈបរិក្ខាបំពាក់អ៊ីនធឺណែតនៅក្នុងបណ្ណាល័យ៖* ការបង្កើតឱ្យមានសម្ភារៈបរិក្ខា ដែលងាយស្រួលចូលប្រើអ៊ីនធឺណែតនៅក្នុងបណ្ណាល័យគឺជាមធ្យោបាយមួយទៀត សម្រាប់សិស្សធ្វើការជាមួយគ្នាលើកិច្ចការផ្សេងៗ។

សម្រាប់សម្ភារៈបរិក្ខាទាំងនេះអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហា ដែលគ្រូដាក់ឱ្យសិស្សដើម្បីបង្កើតការងារគម្រោង និងប្រភពនៃរូបភាពដែលមានសារៈប្រយោជន៍ ព្រមទាំងដ្យាក្រាមនានា។

- *កម្មវិធីសរសេរតាមបណ្តាញ* ផ្តល់នូវវេទិកាសម្រាប់ការសរសេរតាមបែបសហការ។ សិស្សអាចសរសេរទៅកាន់ទស្សនិកជនជាក់ស្តែង ដែលពួកគេអាចឆ្លើយតបភ្លាមៗ និងទៅកាន់អ្នកចូលរួមក្នុងសកម្មភាពសរសេររួមគ្នា។

ចូរបំផុសគំនិតរកយន្តការផ្សេងទៀតដែលបង្ហាញថាបច្ចេកវិទ្យាអាចលើកកម្ពស់ការសហការ និងការផលិតជាផលិតផលសិក្សា ហើយបន្ថែមយន្តការទាំងនោះទៅក្នុងបញ្ជីដែលអ្នកបានសរសេរនៅលើក្តារខៀន។

* * * * * * * * * * * * * * * * *

# មេរៀនទី ៣.៤៖ ការវាយតម្លៃសិស្សតាមបែបស្ថាបនានិយម

**រយៈពេលបង្រៀន** ៖ ២ ម៉ោង

**ការត្រៀមលក្ខណៈ**

- សរសេរលទ្ធផលសិក្សានៃមេរៀននៅលើក្រដាសប៉ុស្ទ័រ
- ថតចម្លង **ឯកសារចែកទី ១០** ៖ ការវាយតម្លៃផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម
- ថតចម្លង **ឯកសារចែកទី១១** ៖ យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម
- ថតចម្លង **ឯកសារចែកទី១២** ៖ ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ក្រដាសប៉ុស្ទ័រ ហ្វឺត
- ក្រដាសប៉ុស្ទ័រដែលសង្ខេបវត្ថុបំណងមេរៀន។
- **ឯកសារចែកទី១០**៖ ការវាយតម្លៃផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម
- **ឯកសារចែកទី១១**៖ យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម
- **ឯកសារចែកទី១២**៖ ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃ ដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម

**លទ្ធផលសិក្សា**

- អ្នកចូលរួមអាច **ពន្យល់** ហេតុអ្វីការសិក្សាបែបស្ថាបនានិយមត្រូវការវិធីសាស្ត្រវាយតម្លៃពិសេសដើម្បីវាយតម្លៃការសិក្សារបស់សិស្ស
- អ្នកចូលរួមអាច **កំណត់** បានពីវិធីសាស្ត្រសំខាន់ៗសម្រាប់ធ្វើការវាយតម្លៃ
- អ្នកចូលរួមអាច **ពណ៌នា** ពីលក្ខណៈពិសេសនៃវិធីសាស្ត្រវាយតម្លៃនីមួយៗ
- អ្នកចូលរួមអាច **ប្រៀបធៀប** ភាពដូចគ្នា និងខុសគ្នារវាងលក្ខណៈពិសេសនៃវិធីសាស្ត្រវាយតម្លៃទាំងនោះ ដោយប្រើប្រាស់តារាងនៅក្នុងឯកសារចែកទី១២ ។

# ផែនការបង្រៀន

## លទ្ធផលសិក្សា

បិតក្រដាសប៉ុសស្ទ័រសង្ខេបពីលទ្ធផលសិក្សាលើក្តារខៀន។ ពន្យល់ពីអ្វីដែលអ្នកចូលរួមទាំងអស់អាចធ្វើបានពេលបញ្ចប់មេរៀននេះ ។

## ដំណើរការ និងផលិតផលនៃការបសិក្សាបែបស្ថាបនានិយម

ដំបូង អ្នកសម្របសម្រួលគួរតែពន្យល់ថា ការប្រើវិធីសាស្រ្តវាយតម្លៃបែបបុរាណ (ឧទាហរណ៍ ៖ ការប្រឡង ការធ្វើតេស្តខ្លីជាដើម ) ដែលមិនសមស្របជាមួយនឹងការវាយតម្លៃតាមបែបស្ថាបនានិយមទេ ព្រោះគ្រូត្រូវយល់ពីដំណើរការនៃការគិតខាងក្នុងរបស់សិស្សដើម្បីបង្កើតផលិតផលសិក្សាណាមួយ។ ដូចនេះហើយ ការយល់ពីរបៀប ឬដំណើរការដែលសិស្សគិតរកដំណោះស្រាយ ឬសេចក្តីសន្និដ្ឋានណាមួយ ពិតជាសំខាន់ មិនខុសអ្វីពីផលិតផលសិក្សា ឬដំណោះស្រាយទាំងនោះទេ ។

បន្ទាប់ពីការពន្យល់ហើយ **ចែកឯកសារចែកទី១០** ដើម្បីជួយអ្នកចូលរួមឱ្យយល់ពីភាពផ្ទុយគ្នារវាងការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម និងការអនុវត្ត។

បន្ទាប់មកទៀត ចែកក្រុមពិភាក្សា ដោយឱ្យអ្នកចូលរួមមើលរូបភាពតុក្កតាក្នុងឯកសារចែក ហើយឆ្លើយសំណួរនៅផ្នែកខាងក្រោមនៃឯកសារ។ ទុកពេលឱ្យពួកគេធ្វើការពិភាក្សាជាក្រុមប្រហែល ១៥ នាទី ។ បន្ទាប់មក ពិនិត្យមើលចម្លើយរបស់ពួកគេជាក្រុមធំ ដើម្បីធានាថា អ្នកចូលរួមទាំងអស់យល់ពីភាពខុសគ្នារវាងការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម ហើយចំណុចខុសគ្នានេះ មានឥទ្ធិពលយ៉ាងដូចម្តេចទៅលើការវាយតម្លៃសិស្ស? ប្រើប្រាស់ចម្លើយដូចខាងក្រោម ដើម្បីជួយសកម្មភាពពិភាក្សាជាក្រុមធំ៖

### សំណួរពិភាក្សា

**១. តើកម្រិតនៃការគិតមានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងការវាយតម្លៃដែលមាននៅក្នុងរូបភាព ក ? នៅក្នុងរូបភាព ខ ? ចូរប្រើសំណួរគាក់សួណ្ឌមីប្លូមដើម្បីរៀបចំចម្លើយរបស់អ្នក។**

*ក. រូបភាព ក៖ ការចងចាំ ការយល់ដឹង ( អាចជាការអនុវត្តផងដែរ)*

*ខ. រូបភាព ខ ៖ ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការបង្កើតថ្មី*

**២. រៀបរាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រវាយតម្លៃដែលមានទាំងក្នុងរូបភាព ក និងរូបភាព ខ។**

ក. រូបភាព ក ៖ គុណសម្បត្តិ

១. ងាយស្រួលវាយតម្លៃតាមរយៈការធ្វើតេស្តងាយៗ និងសួរសំណួរ

២. ទាមទារការវាយតម្លៃដែលសមស្របនឹងប្រព័ន្ធវាយតម្លៃបែបប្រពៃណីរបស់សាលាភាគច្រើន

ខ. រូបភាព ក៖ គុណវិបត្តិ

១. កិច្ចការមិនមានលក្ខណៈប្រកួតប្រជែងជាមួយសមត្ថភាពសិស្ស

២. ការសិក្សាកើតឡើងតែនៅកម្រិតទាបនៃប្លូម

៣. សិស្សមានឱកាសតិចតួចដើម្បីគិតស៊ីជម្រៅ ឬគិតបែបបង្កើតថ្មី

គ. រូបភាព ខ ៖ គុណសម្បត្តិ

១. កិច្ចការមានលក្ខណៈប្រកួតប្រជែងជាមួយសមត្ថភាពសិស្ស

២. សកម្មភាពសិក្សាផ្តល់ឱ្យមានបំណិនគិតកម្រិតខ្ពស់

៣. គ្រូមានការយល់ដឹងច្រើនពីរបៀបសិស្សគិត និង កិច្ចការអ្វីដែលប្រកួតប្រជែងដល់សមត្ថភាពសិស្ស

ឃ. រូបភាព ខ ៖ គុណវិបត្តិ

១. ការអនុវត្តវិធីសាស្ត្រនេះ គឺប្រើប្រាស់ពេលវេលាច្រើ

២. ត្រូវការវិធីសាស្ត្រវាយតម្លៃថ្មីៗ ដែលភាគច្រើនគ្រូមិនទាន់ដឹង

៣. មិនសមស្របជាមួយប្រព័ន្ធវាយតម្លៃបែបប្រពៃណីរបស់សាលាភាគច្រើន

**៣. ហេតុអ្វីបានជាអ្នកគិតថាគ្រូបង្រៀននៅកម្ពុជាមិនប្រើយុទ្ធសាស្ត្រវាយតម្លៃដែលមាននៅក្នុង រូបភាព ខ?**

ក. គ្រូភាគច្រើនផ្តោតទៅលើការប្រឡងបែបប្រពៃណី ដែលមិនសូវជំរុញសិស្សឱ្យមានការគិតបែបស៊ីជម្រៅ

ខ. គ្រូភាគច្រើនមិនទាន់ដឹងពីគោលវិធីការសិក្សាបែបស្ថាបនានិយម និងពីរបៀបវាយតម្លៃតាមគោលវិធីនេះ

គ. គ្រូភាគច្រើនមានសកម្មភាពអាទិភាពនៅក្រៅសាលាច្រើន ហើយមិនមានពេលដើម្បីសិក្សាពីបច្ចេកទេសបង្រៀនដែលមានភាពល្អិតល្អន់ និងបច្ចេកទេសវាយតម្លៃ

ឃ. ផ្សេងៗទៀត

បន្ទាប់ពីការពិភាក្សាខាងលើបានបញ្ចប់ អ្នកសម្របសម្រួលត្រូវចែក **ឯកសារទី ១១** ដើម្បីរំឭកឡើងវិញពីយុទ្ធសាស្ត្រវាយតម្លៃខ្លះៗ តាមបែបស្ថាបនានិយម។ យុទ្ធសាស្ត្រទាំងនោះ រួមមាន៖

- ការវាយតម្លៃបែបឌីណាមិច
- ការវាយតម្លៃកម្រងស្នាដៃសិស្ស
- ការវាយតម្លៃបែបដំណើរការ
- ការវាយតម្លៃបែបក្រៅផ្លូវការ

រំឭកឡើងវិញពីលក្ខណៈពិសេសនៃយុទ្ធសាស្ត្រវាយតម្លៃបែបថ្មីទាំងនេះ ជាមួយអ្នកចូលរួមដោយប្រើប្រាស់ ឯកសារចែក ដែលផ្តល់ឱ្យ។ ពេលកំពុង រំឭក ត្រូវប្រាកដថាអ្នកចូលរួមអាចយល់ពីចំណុចខាងក្រោម៖

- យុទ្ធសាស្ត្រទាំងនេះ ទាមទារឱ្យសិស្សមានការទំនាក់ទំនង និងការចូលរួមច្រើនទាំងជាមួយក្រុម និងគ្រូ ។
- ទំនាក់ទំនងនេះ ភាគច្រើនមានទម្រង់ជាការសម្ភាស ការពិភាក្សាក្រៅផ្លូវការ និងការអង្កេតពីអាកប្បកិរិយារបស់ពួកគេម្នាក់ៗជាមួយសិស្សដទៃទៀត ។
- ការសិក្សាផ្តោតខ្លាំងទៅលើសកម្មភាពរៀន ផលិតផលសិក្សាជាក់ស្តែង និងដំណោះស្រាយ ពេលធ្វើការងារដែលគ្រូដាក់ឱ្យ ។
- ជាញឹកញាប់ វាអាចមានភាពជាន់គ្នាច្រើនជាមួយចរិតលក្ខណៈនៃយុទ្ធសាស្ត្រផ្សេងៗទៀត
- យុទ្ធសាស្ត្រទាំងនេះ អាចបំពេញបន្ថែមលើការវាយតម្លៃបែបផ្លូវការ ដោយវាផ្តល់ព័ត៌មានពីការសិក្សារបស់សិស្ស។

បន្ទាប់មកទៀត អ្នកសម្របសម្រួលអាចពន្យល់បន្ថែមទៅលើការពិភាក្សាខាងលើ ដោយផ្តល់ឧទាហរណ៍ជាក់ស្តែងពីយុទ្ធសាស្ត្រវាយតម្លៃក្នុង **ឯកសារចែកទី ១១**។ បន្ទាប់មក ចែក**ឯកសារទី ១២** ហើយពន្យល់ពីឧទាហរណ៍នៃយុទ្ធសាស្ត្រនីមួយៗ

ក្រោយពីការពន្យល់នេះ ឱ្យអ្នកចូលរួមចូលតាមក្រុមតូច ហើយពិភាក្សាបំពេញលំហាត់នៅចុងឯកសារចែកទី ១២ ។ ទុកពេលឱ្យពួកគេ ២០ នាទីសម្រាប់លំហាត់នេះដោយឱ្យពួកគេបំពេញចម្លើយនៅលើក្រដាសប៉ុស្ទ័រ។

ពេលក្រុមនីមួយៗបំពេញចម្លើយអស់ហើយ ឱ្យពួកគេបិតក្រដាសនៅលើជញ្ជាំង ដើម្បីប្រៀបធៀបចម្លើយគ្នា។ ប្រើប្រាស់ចម្លើយខាងក្រោម ដើម្បីជាជំនួយឱ្យអ្នកចូលរួមអាចយល់បានចំណុចសំខាន់ៗពេលធ្វើការពិភាក្សាក្រុមធំ៖

| **កត្តា** | **ការវាយតម្លៃបែបឌីណាមិច** | **ការវាយតម្លៃលើកម្រងស្នាដៃសិស្ស** | **ការវាយតម្លៃបែបដំណើរការ** | **ការវាយតម្លៃក្រៅផ្លូវការ** |
|---|---|---|---|---|
| **ពេលវេលា** (ឧ. មុន អំឡុងពេល ចុងបញ្ចប់នៃកិច្ចការ) | ធ្វើជាប្រចាំ | ចុងបញ្ចប់ | ធ្វើជាប្រចាំ | ធ្វើជាប្រចាំ |
| **ការផ្តោតលើផលិតផល** (ឧ. ខ្ពស់ ទាប ។ល។) | មធ្យម | ខ្ពស់ | ទាប | មធ្យម |
| **ការផ្តោតលើដំណើរការ** (ឧ. ខ្ពស់ ទាប ។ល។) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| **អន្តរកម្មគ្រូបង្រៀន** (ឧ. ខ្ពស់ ទាប ។ល។) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| **ប្រើបច្ចេកទេសវាយតម្លៃផ្លូវការ** (ឧ. បញ្ជីផ្ទៀងផ្ទាត់ តេស្ត ។ល។) | មធ្យម | ខ្ពស់ | មធ្យម | ទាប |

# ឯកសារចែក

## សម្រាប់

# សិក្ខាកាម

## ឯកសារចែកទី១៖ ការផ្សារភ្ជាប់រវាងការសិក្សាតាមបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀត

- ការសិក្សាតាមបែបស្ថាបនានិយម គឺជាទ្រឹស្តីទូលំទូលាយមួយ ដែលបញ្ចូលគ្នានូវបញ្ញត្តិផ្សេងៗជាច្រើន។
- គោលការណ៍ស្នូលនៃការសិក្សាបែបស្ថាបនានិយមគឺផ្តោតលើសមត្ថភាពរបស់សិស្សក្នុងការ **បង្កើតបញ្ញត្តិ** ទន្ទឹមនឹងនោះក៏មានធាតុពាក់ព័ន្ធជាច្រើនពីវិធីសាស្ត្រផ្សេងៗទៀតដែលរួមមានការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសិក្សាបែបសហការ ការប្រើប្រាស់បច្ចេកវិទ្យា និងវិធីសាស្ត្រដទៃជាច្រើនទៀត។




### សំណួរសម្រាប់ការពិភាក្សា

- តើអ្នកធ្លាប់ដឹងទ្រឹស្តីសិក្សាទាំងនេះពីមុនមកឬទេ? ដោយផ្អែកលើអ្វីដែលអ្នកដឹងរហូតមកដល់ពេលនេះ តើអ្នកអាចពន្យល់ ថាតើវាមានទំនាក់ទំនងដូចម្តេចទៅនឹងការសិក្សាតាមបែបស្ថាបនានិយម?
- តើហេតុអ្វីបានជាអ្នកគិតថា "ការសហការ" មានសារៈសំខាន់សម្រាប់ការបង្កើតបញ្ញត្តិ និងគំនិតថ្មីៗ?
- តើអ្នកគិតថា Bloom's Taxonomy មានទំនាក់ទំនងអ្វីខ្លះ ទៅនឹងការសិក្សាតាមបែបស្ថាបនានិយម?
- តើអ្នកគិតថាបច្ចេកវិទ្យាអាចលើកកម្ពស់ការសិក្សាតាមបែបស្ថាបនានិយមបានដោយរបៀបណា?



# ឯកសារចែកទី២ក៖ និយមន័យការសិក្សាបែបស្ថាបនានិយម

## និយមន័យ

ការសិក្សាបែបស្ថាបនានិយម មានន័យថាសិស្សសហការគ្នា **ស្ថាបនា** ចំណេះដឹងរបស់ពួកគេ ចេញពីបទពិសោធន៍ និងការគិតលើបទពិសោធន៍ទាំងនេះ (ការឆ្លុះបញ្ចាំង)។ គំរូការសិក្សាតាមបែបស្ថាបនានិយម បញ្ជាក់ថាអ្នកសិក្សាគួរតែមានភាពម្ចាស់ការឱ្យបានច្រើន (ពោលគឺ ជាអ្នកដឹកនាំខ្លួនឯង) លើដំណើរការសិក្សា ជាង "ថ្នាក់រៀនដែលបង្រៀនតាមបែបប្រពៃណី" ហើយសិស្សម្នាក់រៀនកាន់តែពូកែ នៅពេលដែលពួកគេស្រាវជ្រាវអ្វីមួយដោយខ្លួនឯង។[2]




ដ្យាក្រាមខាងលើ ផ្តល់នូវអត្ថន័យច្បាស់លាស់សម្រាប់និយមន័យនៃការសិក្សាបែបស្ថាបនានិយម។ យោងតាមដ្យាក្រាមនេះ ប្រសិនបើអ្នក៖

- ចូលរួមយ៉ាងសកម្មក្នុងកិច្ចការដែលអ្នកជ្រើសរើសធ្វើ (ដឹកនាំខ្លួនឯង)
- ឆ្លុះបញ្ចាំងអំពីព័ត៌មានថ្មី និងបទពិសោធន៍ពីមុន
- បន្ថែមគំនិតថ្មីផ្អែកលើការសហការគ្នាជាមួយក្រុមការងារ
- និង … បង្កើតបញ្ញត្តិថ្មី ដោយផ្អែកលើការឆ្លុះបញ្ចាំងរបស់អ្នក

**នៅពេលនោះ គឺអ្នកកំពុងតែរៀន តាមបែបស្ថាបនានិយម ហើយ។**

[2] https://bc.instructure.com/courses/829527/pages/theory-constructivist-learning

# លំហាត់

**សេចក្តីណែនាំ៖ សទិសភាព** គឺជាការប្រៀបធៀបពាក្យពីរគូ ដែលមានទំនាក់ទំនងស្រដៀងគ្នាមួយ។ សូមមើលឧទាហរណ៍ខាងក្រោម។

***ឧទាហរណ៍ទី១៖*** ឪពុក ជាគូនឹង កូនប្រុស (គូទី១ ) ក៏ដូចជា ម្តាយ ជាគូនឹង កូនស្រី (គូទី២)

តើគូទាំងពីរនេះមានទំនាក់ទំនងអ្វីនឹងគ្នា? កូនដែលមានភេទដូចឪពុកម្តាយ

***ឧទាហរណ៍ទី២៖*** ស្លាប ជាគូនឹង យន្តហោះ ក៏ដូចជា ក្តោង ជាគូនឹង ទូក

តើគូទាំងពីរនេះមានទំនាក់ទំនងអ្វីនឹងគ្នា? មធ្យោបាយជួយរុញច្រានអ្វីមួយឱ្យទៅមុខ

*តាមរយៈឧទាហរណ៍ខាងលើសូមធ្វើការជាក្រុមសាកល្បងបង្កើតសទិសភាពឱ្យបាន៤ បន្ថែមទៀតដែលបង្ហាញពីទំនាក់ទំនងស្រដៀងគ្នា។*

***សទិសភាព១៖*** ________ *ជាគូនឹង* _______ *ក៏ដូចជា*_______ *ជាគូនឹង* __________

***សទិសភាព២៖*** ________ *ជាគូនឹង* _______ *ក៏ដូចជា*_______ *ជាគូនឹង* __________

***សទិសភាព៣៖*** ________ *ជាគូនឹង* _______ *ក៏ដូចជា*_______ *ជាគូនឹង* __________

***សទិសភាព៤៖*** ________ *ជាគូនឹង* _______ *ក៏ដូចជា*_______ *ជាគូនឹង* __________

*នៅពេលអ្នកបានធ្វើចប់ សូមចែករំលែកសទិសភាពទាំងនោះ ជាមួយក្រុមធំ ។*

*បន្ទាប់មក រៀបរាប់របៀបដំណើរការលំហាត់នេះ ដោយឆ្លុះបញ្ចាំងពីការសិក្សាបែបស្ថាបនានិយម ដោយឆ្លើយតបតាមសំណួរខាងក្រោម៖*

*តើអ្នកបានធ្វើអ្វីខ្លះក្នុងលំហាត់នេះ ដែលឆ្លុះបញ្ចាំងពីធាតុផ្សេងៗនៃការសិក្សបែបស្ថាបនានិយម?*

១. សកម្មភាពដឹកនាំខ្លួនឯង៖

______________________________________________________________

២. ការឆ្លុះបញ្ចាំងពីបទពិសោធន៍ពីមុន និងព័ត៌មានថ្មី៖

______________________________________________________________

៣. ការសហការគ្នាដើម្បីបង្កើនគំនិតឱ្យបានច្រើន៖

______________________________________________________________

៤. បង្កើតចំណេះដឹង និងបញ្ញត្តិថ្មីៗ៖

______________________________________________________________

## ឯកសារចែកទី២ខ៖ គោលការណ៍គន្លឹះនៃការសិក្សាបែបស្ថាបនានិយម

*ទាំងនេះគឺជាគោលការណ៍គន្លឹះមួយចំនួន អំពីការអនុវត្តការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀន៖*

- **ការសិក្សាបែបអន្តរកម្ម៖** ជាធម្មតា មនុស្សរៀន និងធ្វើការដោយសហការគ្នានៅក្នុងជីវិតរបស់ពួកគេ។ អន្តរអំពើជាវិធីមួយក្នុងការលើកទឹកចិត្ត និងជំរុញអ្នកសិក្សា។ វាផ្តល់នូវវិធីមួយតាមរយៈសកម្មភាព និងការពិភាក្សាសម្រាប់គ្រូ ដើម្បីជំរុញអ្នកសិក្សាឱ្យចេះពិចារណា និងឆ្លុះបញ្ចាំងលើខ្លឹមសារ និងដំណើរការសិក្សា។ អន្តរកម្មរវាងគ្រូបង្រៀន សិស្ស និងខ្លឹមសារដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាបែបស្ថាបនានិយម។

  **ឧទាហរណ៍៖** សិស្សធ្វើការជាក្រុមក្នុងថ្នាក់រៀន ធ្វើគម្រោងជាក្រុម បណ្តាញអ៊ីនធឺណែត ក្លឹបសិក្សាមុខវិជ្ជា ការចុះសម្ភាសដល់មូលដ្ឋានដើម្បីប្រមូលព័ត៌មានសម្រាប់គម្រោងមួយ ។ល។

- **ការសិក្សាបែបសម្របសម្រួល៖** បង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់អ្នកសិក្សាដើម្បីឱ្យពួកគេបញ្ចេញគំនិតដោយសេរី ចែករំលែកគំនិត និងសួរសំណួរ។ គ្រូនៅក្នុងមជ្ឈដ្ឋានសិក្សាបែបស្ថាបនានិយម មានទំនួលខុសត្រូវពិនិត្យតាមដាន ធានាគុណភាពសិក្សា និងពិភាក្សាជាក្រុម។ វាគឺជាការចាំបាច់ណាស់សម្រាប់គ្រូបង្រៀនក្នុងការគាំទ្រ និងណែនាំឱ្យបានគ្រប់គ្រាន់ដល់សិស្សដែលរៀនតាមបណ្តាញអ៊ីនធឺណែត។

  **ឧទាហរណ៍៖** គ្រូបង្រៀនដើរតួជា "អ្នកសម្របសម្រួលក្នុងការសិក្សា" មិនមែនជាគ្រូឧទ្ទេសទេ គ្រូបង្រៀនដើរតួជាទីប្រឹក្សា ដល់ក្លឹបមុខវិជ្ជាដែលដឹកនាំដោយសិស្ស ជាដើម។

- **ការសិក្សាបែបជាក់ស្តែង៖** ការសិក្សាតាមបែបស្ថាបនានិយម សង្កត់ធ្ងន់លើការសិក្សាណាដែលមានលក្ខណៈជាក់ស្តែង និងឆ្លើយតបទៅនឹងបទពិសោធន៍ជីវិតជាក់ស្តែង។ បរិយាកាសសិក្សានេះ គួរតែផ្តល់នូវពិភពពិតជាក់ស្តែង ការសិក្សាអាស្រ័យលើករណីជាក់ស្តែង ដើម្បីទទួលបាននូវចំណេះដឹងពិតជាក់ស្តែង និងមានអត្ថន័យ។

  **ឧទាហរណ៍៖** ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រ សារមន្ទីរ រោងចក្រ ។ល។ ការពិសោធវិទ្យាសាស្ត្រ ដែលដឹកនាំដោយសិស្ស ។ល។

- **ការសិក្សាបែបសិស្សមជ្ឈមណ្ឌល៖** ជាធម្មតា សិស្សដែលចេះដឹកនាំខ្លួនឯង មានការជំរុញទឹកចិត្តខ្ពស់ ដឹងពីអ្វីដែលពួកគេចង់រៀន ចេះកំណត់វត្ថុបំណង ស្វែងរកធនធាន និងវាយតម្លៃដំណើរការសិក្សា ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។

  **ឧទាហរណ៍៖** សិស្សជ្រើសរើសប្រធានបទដែលពួកគេចង់សិក្សា។ សិស្សអាចប្រកាសមុខវិជ្ជារៀន ដូចជាគីមីវិទ្យា រូបវិទ្យា និងមុខវិជ្ជាផ្សេងទៀត តាមចំណាប់អារម្មណ៍។ សិស្សជ្រើសរើសចូលរួមក្លឹបសិក្សាមុខវិជ្ជា ដែលពួកគេចាប់អារម្មណ៍បំផុត។ ក្រុមការងារគម្រោងជ្រើស

រើសយកប្រធានបទផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ធ្វើការស្រាវជ្រាវ ។ល។

- **ការសិក្សាដែលមានគុណភាពខ្ពស់៖** -ការសិក្សាបែបស្ថាបនានិយម គួរតែពាក់ព័ន្ធនឹងបំណិនគិតកម្រិតខ្ពស់ ដែលសិស្សត្រូវធ្វើការវាយតម្លៃ និងសំយោគព័ត៌មាន។ អ្នកសិក្សាត្រូវតែរៀនពីរបៀបគ្រប់គ្រង វិភាគ រិះគន់ ប្រៀបធៀបឯកសារយោង និងប្រែក្លាយព័ត៌មានទៅជាចំណេះដឹងដ៏មានតម្លៃ។

  **ឧទាហរណ៍៖** សិស្សបង្កើតបទបង្ហាញជា PowerPoint ផ្ទាល់ខ្លួន។ សិស្សនិពន្ធកំណាព្យផ្ទាល់ខ្លួន រឿងនិទាន និងសំណេរបែបច្នៃប្រឌិតផ្សេងទៀត។ សិស្សសរសេររបាយការណ៍ឬធ្វើជាសៀវភៅ វិភាគអត្ថន័យសាច់រឿងមួយដែលពួកគេបានអាន ។ល។

## លំហាត់៖

**សេចក្តីណែនាំ៖** ការសិក្សាបែបស្ថាបនានិយម គឺជាការបង្កើតបញ្ញត្តិថ្មី និងមតិយោបល់នានាតាមរយៈការឆ្លុះបញ្ចាំងលើ**ចំណេះដឹងថ្មី** និង**បទពិសោធន៍ពីមុន**របស់ខ្លួន។ សូមសហការជាមួយក្រុមរបស់អ្នក ដើម្បីបង្កើតដ្យាក្រាមដែលបង្ហាញពីការយល់ដឹងរបស់អ្នកចំពោះបញ្ញត្តិសំខាន់ៗ ដែលកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម និងទំនាក់ទំនងគ្នានៃបញ្ញត្តិទាំងនោះ។ មានដ្យាក្រាមច្រើនប្រភេទ ដែលអ្នកអាចប្រើសម្រាប់ធ្វើលំហាត់នេះ។ ឧទាហរណ៍ ដ្យាក្រាមមួយចំនួនមានផ្តល់ជូនដូចខាងក្រោម។ ដើម្បីបង្ហាញពីការយល់ដឹងរបស់អ្នក មិនមែនមានតែមធ្យោបាយត្រឹមត្រូវតែមួយនោះទេ ក្រុមផ្សេងគ្នា អាចបង្កើតដ្យាក្រាមផ្សេងគ្នា ដើម្បីបកស្រាយផ្សេងៗគ្នាផងដែរ។












## ឯកសារចែកទី៣៖ ហេតុអ្វីការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព?

- ដ្យាក្រាមខាងក្រោមបង្ហាញពីកម្រិតចូលរួមរបស់យើងក្នុងសកម្មភាពសិក្សា និងបរិមាណនៃការចងចាំរបស់យើងបន្ទាប់ពីចូលរួមកិច្ចការទាំងនោះ។
- កិច្ចការសិក្សានៅផ្នែកខាងក្រោមនៃពីរ៉ាមីត អាចជួយឱ្យយើងចងចាំបាន ៥០% ឬច្រើនជាងនេះនូវអ្វីដែលយើងបានរៀន ចំណែកឯកិច្ចការសិក្សានៅផ្នែកខាងលើនៃពីរ៉ាមីតអាចឱ្យយើងចងចាំតិចជាង ៥០% ។
- យើងមិនគួរយល់ច្រឡំថា ដ្យាក្រាមនេះចង់ឱ្យគ្រូបង្រៀនគួរតែជៀសវាងហៅសិស្សឱ្យ "អាន" ឬ "ស្តាប់" ការឧទ្ទេសនោះទេ។ ផ្ទុយទៅវិញដ្យាក្រាមនេះចង់ពន្យល់ថា កិច្ចការទាំងនេះគួរតែផ្គូរជាមួយនឹងកិច្ចការសកម្មៗជាច្រើនទៀត ដើម្បីពង្រឹងចំណេះដឹងឱ្យកាន់តែប្រសើរ។
- ប្រើដ្យាក្រាមដែលបានផ្តល់ជូន ដើម្បីបំពេញកិច្ចការក្នុងលំហាត់ខាងក្រោម៖



# លំហាត់

*សេចក្តីណែនាំ៖ សូមព្យាយាមបំពេញកិច្ចការខាងក្រោមដោយកំណត់កិច្ចការ "សកម្ម" ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចការ "អកម្ម"។ កិច្ចការអកម្មត្រូវបានផ្តល់ជូនរួចហើយនៅខាងក្រោមសម្រាប់អ្នក។ ឧទាហរណ៍មួយត្រូវបានផ្តល់ជូនសម្រាប់អ្នកផងដែរ។*

| | **កិច្ចការ អកម្ម** | **កិច្ចការ សកម្ម** (ពង្រឹងចំណេះដឹង) |
|---|---|---|
| ឧ. | **កិច្ចការទី១៖** អានសៀវភៅអំពីប្រវត្តិអង្គរ | **កិច្ចការទី២៖** អនុញ្ញាតឱ្យសិស្សក្នុងថ្នាក់ឡើងនិយាយពីសៀវភៅដែលបានអានអំពីប្រវត្តិអង្គរ |
| ១ | **កិច្ចការទី១៖** ស្តាប់គ្រូអំពីអគ្គិសនីវិភាគ | **កិច្ចការទី២៖** ??? |
| ២ | **កិច្ចការទី១៖** មើលឯកសារអំពីរបៀបដែលបេះដូងដំណើរការ | **កិច្ចការទី២៖** ??? |
| ៣ | **កិច្ចការទី១៖** មើលវីដេអូអំពីការធ្វើបង្អែមខ្មែរ | **កិច្ចការទី២៖** ??? |
| ៤ | **កិច្ចការទី១៖** ស្តាប់គ្រូឧទ្ទេសអំពីគ្រោះថ្នាក់នៃការសេពគ្រឿងញៀន | **កិច្ចការទី២៖** ??? |
| ៥ | **កិច្ចការទី១៖** សង្កេតមើលការតាំងពិព័រណ៍អំពីរបៀបដែលជ័រកៅស៊ូត្រូវបានកែច្នៃនៅក្នុងរោងចក្រ | **កិច្ចការទី២៖** ??? |

# ឯកសារចែកទី៤៖ ការផ្សាភ្ជាប់រវាងការសិក្សាបែបស្ពានិយម និង Bloom's Taxonomy




## ការពិភាក្សា

- កិច្ចការនៃការសិក្សាបែបស្ពានិយម ជាទូទៅកើតឡើងនៅកម្រិតកាន់តែខ្ពស់នៅក្នុង BLOOM។

| | | | | |
|---|---|---|---|---|
| វិភាគ | ស្រាវជ្រាវតាមអ៊ីនធឺណែត | ធ្វើពិសោធវិភាគកង្កែប | បង្កើតដ្យាក្រាមមូលហេតុប្រវត្តិសាស្ត្រ | ពិភាក្សាការងារជាក្រុម |
| វាយតម្លៃ | វាយតម្លៃ របាយការណ៍សៀវភៅ | កំណត់ និងអនុវត្តស្តង់ដា | ធ្វើអាទិភាពបញ្ជីការងារ | រិះគន់ស្នាដៃប្រវត្តិសាស្ត្រ |
| បង្កើត | បង្កើតអត្ថបទកំណាព្យ | តាំងពិព័រណ៍ | ធ្វើបទបង្ហាញ | ព្យាករណ៍វិបាក |

- កិច្ចការក្នុងការសិក្សាបែបស្ពានិយមនៅកម្រិតស្មុគស្មាញនេះ ជាញឹកញាប់តម្រូវឱ្យមានការរៀបផែនការរយៈពេលវែង ការប្រជុំ ការពិភាក្សា និងការកែប្រែច្រើនដងទៅលើផលិតផលសិក្សា ។
- ការសួរសំណួរកម្រិតខ្ពស់ ជំរុញឱ្យសិស្សស្ថាបនាបញ្ញត្តិផ្ទាល់ខ្លួនលើសម្ភារៈថ្មីៗ។ គេមិនអាចស្គាល់សម្ភារៈបានទេ រហូតដល់ពួកគេយល់បញ្ញត្តិវាជាមុនសិន ដូច្នោះសំណួរដែលជំរុញឱ្យមានការគិតរកហេតុផលគឺជួយជំរុញបង្កើតបញ្ញត្តិ។
- ខាងក្រោមនេះជាគោលការណ៍ណែនាំមួយចំនួនសម្រាប់សួរសំណួរដែលគាំទ្រដល់ការសិក្សាបែបស្ពានិយម៖

## វិភាគ

| | |
|---|---|
| **សំណួរ "របៀបណា និង ហេតុអ្វី"** | *-តើហេតុអ្វីអាកាសធាតុផ្លាស់ប្ដូរ?*<br>*-តើជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់ដូចគ្នា និងខុសគ្នាដូចម្ដេច?* |

## វាយតម្លៃ

| | |
|---|---|
| **សំណួរ "វិនិច្ឆ័យ"** | *-តើអ្នកណាជាមនុស្សអស្ចារ្យបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ?* |

## បង្កើតថ្មី

| | |
|---|---|
| **សំណួរ "មានអ្វីកើតឡើង ប្រសិនបើ..."** | *-ប្រសិនបើអ្នកជាព្រះបាទជ័យវរ្ម័នទី ៧ តើអ្នកនឹងកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្ដេច?* |

## លំហាត់

***សេចក្ដីណែនាំ៖*** បង្កើតសំណួរមួយសម្រាប់មុខវិជ្ជាមួយដែលអ្នកជ្រើសរើស ដែលគាំទ្រដល់ការសិក្សាបែបស្ថាបនានិយមសម្រាប់ប្រភេទនៃការគិតនីមួយៗក្នុងបញ្ជីខាងក្រោម៖

| មុខវិជ្ជា៖ ________ | មុខវិជ្ជា៖ _________ | មុខវិជ្ជា៖ ________ |
|---|---|---|
| វិភាគ | វាយតម្លៃ | បង្កើតថ្មី |
| ______________________________? | ____________________________? | ___________________________? |

## ឯកសារចែកទី៥ក៖ ការបង្កើតបញ្ញត្តិ[3] និងការសិក្សាបែបស្ថាបនានិយម

**សេចក្តីផ្តើម៖** ការសិក្សាបែបស្ថាបនានិយម ផ្តោតលើការបង្កើតលក្ខខណ្ឌដែលសិស្សអាចបង្កើតបញ្ញត្តិដោយធ្វើការរួមបញ្ចូលគ្នានូវទិន្នន័យ ឬព័ត៌មានផ្សេងៗទៅជាទម្រង់ថ្មី និងគួរចាប់អារម្មណ៍ ។

**និយមន័យនៃការបង្កើតបញ្ញត្តិ៖** ការបង្កើតបញ្ញត្តិគឺជាដំណើរការមួយដែលលើកទឹកចិត្តឱ្យសិស្សចេះរៀបចំព័ត៌មានជាក្រុម ឬជាប្រភេទ រួមមានជា ពាក្យ រូបភាព រូបមន្ត ឬដំណើរការដោយផ្អែកលើលក្ខណៈពិសេសរួមគ្នា។

### ជំហានទូទៅក្នុងការបង្កើតបញ្ញត្តិ ៖

**ជំហានទី១៖** គ្រូបង្ហាញទិន្នន័យ ឬ ឱ្យសិស្សជួយបង្កើតទិន្នន័យ

**ជំហានទី២៖** សិស្សចងក្រុមទិន្នន័យជាប្រភេទក្រុម ដោយកំណត់លក្ខណៈរួមគ្នា ឬលក្ខណៈវិនិច្ឆ័យអ្វី ដែលឱ្យគេអាចដាក់ទិន្នន័យក្នុងក្រុមរួមគ្នា។

**ជំហានទី៣៖** តាមរយៈសំណួរ និងការពិភាក្សា សិស្សកំណត់ឈ្មោះប្រភេទក្រុមទិន្នន័យ

**ជំហានទី៤៖** សិស្សចែករំលែកការរកឃើញរបស់ពួកគេអំពីប្រភេទក្រុម ព្រមទាំងរបៀបដែលពួកគេដាក់ចូលក្នុងប្រភេទក្រុម។

### ការពិចារណាលើការគ្រប់គ្រងថ្នាក់រៀន៖

- ធ្វើការជាក្រុម
- ការកំណត់ទិន្នន័យអាចត្រូវបានធ្វើឡើងជាមុន (ដោយគ្រូ) ឬកំណត់ដោយសិស្សក្នុងថ្នាក់
- មធ្យោបាយដែលមានប្រសិទ្ធិភាពក្នុងការង្ហាញរួមមាន ដ្យាក្រាម ផែនទីគំនិត ផែនទីបញ្ញត្តិ និងតារាងរចនាសម្ព័ន្ធ ។ល។




### អត្ថប្រយោជន៍៖

- ផ្តល់ឱ្យសិស្សនូវបទពិសោធន៍ក្នុងការកំណត់ទំនាក់ទំនង នៅពេលដាក់ទិន្នន័យជាក្រុម
- ជួយសិស្សឱ្យយល់ពីខ្លឹមសារព័ត៌មាន

[3] http://www.tvdsb.ca/webpages/tkernaghan/educatorresources.cfm?subpage=190909

- សម្រួលការចងចាំព័ត៌មានពេលវាស្ថិតនៅក្នុងទម្រង់ជារូបភាព ជាពិសេសមានប្រយោជន៍សម្រាប់អ្នករៀនចេះតាមរយៈរូបភាព។

## លំហាត់

បង្កើតផែនទីគំនិតដែលបញ្ជាក់ពីប្រភេទភាសាផ្សេងៗនៃប្រទេសកម្ពុជា។ ប្រើពណ៌ផ្សេងគ្នាដើម្បីជួយបែងចែករវាងក្រុមភាសាដែលផ្សេងគ្នា។ អ្នកក៏អាចបែងចែកភាសាទៅតាមសំឡេងឡើងចុះ (tonal), ការប្រើតួអក្សរឡាតាំង ។ល។ ដែរឬទេ? សូមពិនិត្យរកមើលព័ត៌មានក្នុងតារាងនេះ និងនៅលើបណ្ដាញអ៊ីនធឺណែត។

### ទិន្នន័យមុនពេលបង្កើត

| អូស្ត្រូអាស៊ី | អូស្ត្រូណេស៊ី | ស៊ីណូ-ទីបេ | តៃ-កាដៃ | ឥណ្ឌូ-អឺរ៉ុប |
|---|---|---|---|---|
| ខ្មែរ | ម៉ាឡេ | ចិន | ថៃ | អង់គ្លេស |
| មន | ចាម | វៀតណាម | ឡាវ | បារាំង |
| ព្នង | | ភូមា | អ៊ីសាន | បាលី |
| ទំពួន | | | | |
| គ្រឹង | | | | |
| គួយ | | | | |
| ស្ទៀង | | | | |

* * * * * * * * * * * * * * * * *

## ឯកសារចែកទី៥ខៈ ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ




*សំណួរសម្រាប់ការស្រាវជ្រាវ៖* តើកត្តាអ្វីដែលបង្កឱ្យមានការចុះខ្សោយនៃអាណាចក្រអង្គ?

- *សារ់តាៈ* មានទ្រឹស្តីខុសៗគ្នាជាច្រើនស្តីពីមូលហេតុដែលអាណាចក្រអង្គរធ្លាក់ចុះនៅក្នុងសតវត្សរ៍ទី១៥ នេះ។ មូលហេតុចម្បងបំផុត គឺការឈ្លានពានរបស់ថៃនៅក្នុងឆ្នាំ១៤៣១ ដែលជាលទ្ធផល ទីក្រុងរាជធានីអង្គររងការបំផ្លិចបំផ្លាញជាទ្រង់ទ្រាយធំ ហើយនៅទីបំផុត ក៏មានការសម្រេចចិត្តបោះបង់ចោលរាជធានីមកនៅទីតាំងថ្មីមួយដែលស្ថិតនៅជិតតំបន់រាជធានីភ្នំពេញសព្វថ្ងៃនេះ។
- *កិច្ចការ៖* ធ្វើការស្រាវជ្រាវរកមូលហេតុនៃការចុះខ្សោយនៃអាណាចក្រអង្គរ និងបង្កើតផែនទីកត្តា (ហេតុ និងផល) ដែលពន្យល់ថាតើកត្តាទាំងនេះមានទំនាក់ទំនងគ្នាដូចម្តេច ហើយវាធ្វើឱ្យមានការដួលរលំនៃអាណាចក្រអង្គរដោយរបៀបណា?
- **ទិន្នន័យដែលត្រូវពិចារណា**



| | |
|---|---|
| ✚ សង្គ្រាម | ✚ អរិភាពនៃប្រទេសថៃ |
| ✚ ការឈ្លានពាន | ✚ ការផ្លាស់ប្តូរជាសាកលផ្នែកសេដ្ឋកិច្ចតាមផ្លូវសមុទ្រ |
| ✚ កម្សោយនៃភាពដឹកនាំ | ✚ គ្រោះទុរភិក្ស |
| ✚ ការប្រែប្រួលអាកាសធាតុ | ✚ អស្ថេរភាពសេដ្ឋកិច្ច |
| ✚ គ្រោះរាំងស្ងួត | ✚ ការបែកបាក់ផ្ទៃក្នុង |
| ✚ ការផ្លាស់ប្តូរទៅកាន់ព្រះពុទ្ធសាសនាថេរវាទ | |

**ការបង្កើតបញ្ញត្តិដោយក្រុមទី១**



## ការបង្កើតបញ្ញត្តិដោយក្រុមទី២




## សំណួរសម្រាប់ពិភាក្សា

១. តើផែនទីបញ្ញត្តិទាំងពីរនេះដូចគ្នាបែបណាខ្លះ?

២. តើផែនទីបញ្ញត្តិ ដែលបង្កើតឡើងដោយក្រុមនីមួយៗខុសគ្នារបៀបណា? (ឧ. តើក្រុមណាបានបង្កើតផែនទីដែលមានបញ្ញត្តិច្រើនជាង? តើផែនទីទាំងពីរ មានទំនាក់ទំនងរវាងបញ្ញត្តិសមហេតុផលឬទេ? ។ល។)

៣. តើអ្នកគិតថាសិស្សដែលប្រើពណ៌ផ្សេងគ្នាក្នុងផែនទីរបស់ពួកគេចង់និយាយពីអ្វី?

៤. តើយើងអាចនិយាយថា ផែនទីបញ្ញត្តិមួយណា ឬទាំងពីរត្រឹមត្រូវ ឬខុសបានទេ? ហេតុអ្វីត្រឹមត្រូវ? ហេតុអ្វីមិនត្រឹមត្រូវ?

* * * * * * * * * * * * *

# ឯកសារចែកទី៦៖ យុទ្ធសាស្ត្របង្រៀនល្អៗ មួយចំនួនសម្រាប់ការសិក្សាបែបស្ថាបនានិយម [4]

## គោលការណ៍ណែនាំទូទៅ

- ប្រើយុទ្ធសាស្ត្របង្រៀនដែលតម្រូវឱ្យសិស្សបង្កើត គំនិត ឬបញ្ញត្តិ បាន។ (ការបង្ហាញតែព័ត៌មានគឺមិនគ្រប់គ្រាន់ទេ។) សិស្សត្រូវតែអនុវត្ត ប្រើប្រាស់ ឬធ្វើដំណើរការព័ត៌មាននេះ។
- ធានាថាសិស្សទាំងអស់នឹងចូលរួមក្នុងការបង្កើតគំនិត ដោយមានការទទួលខុសត្រូវចំពោះការសិក្សារៀងៗខ្លួន។
- ធានាថាកិច្ចការទាំងឡាយតម្រូវឱ្យសិស្សគិតពីព័ត៌មាននៅកម្រិតខ្ពស់តាម Bloom's taxonomy ៖ ការវិភាគ ការវាយតម្លៃ និងការបង្កើតថ្មី។
- តម្រូវឱ្យសិស្សបង្កើតផលិតផលដែលត្រូវប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃទៅលើកំហុស និងភាពខ្វះខាតនៃការសិក្សា។ ឧ.សន្ទនាជាមួយដៃគូ ផ្គូរផ្គងបណ្ណ និងលំហាត់សរសេរផ្សេងៗ
- តម្រូវឱ្យសិស្សពិនិត្យរកមើលកំហុស និងភាពខ្វះខាតនៃការសិក្សារបស់ខ្លួនឯងផ្ទាល់ផង និងរបស់ដៃគូផង។
- តម្រូវឱ្យសិស្សកែតម្រូវលើកំហុស និងភាពខ្វះខាតនៃការសិក្សាទាំងនេះ។

## បច្ចេកទេសមួយចំនួនក្នុងសម្រេចបាននូវយុទ្ធសាស្ត្រខាងលើ

**ការសម្រេចចិត្ត-ការសម្រេចចិត្ត** ( Decisions-Decisions)

សិស្សធ្វើការជាដៃគូ សិក្សា អត្ថបទ វីដេអូ ។ល។ ដែលបានផ្តល់ឱ្យ រួមជាមួយ៖

**បណ្ណការពិតសង្ខេប** (Summary Facts Cards) ដែលជួយសង្ខេបចំណុចគន្លឹះៗពីអត្ថបទមួយដែលចំណុចខ្លះពិត ហើយខ្លះទៀតមិនពិត។ ឧទាហរណ៍៖

- ពាក្យថាវ៉ាំឡង់ សំដៅទៅលើចំណងរវាងអាតូម
- វ៉ាំឡង់ជាធម្មតាត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌនៃចំនួនអប្បបរមារបស់អាតូមអ៊ីដ្រូសែនដែលធាតុមួយផ្សេងទៀតអាចភ្ជាប់ជាមួយបាន។

**បណ្ណលទ្ធផល** (Consequence Cards) ៖ បង្ហាញពីលទ្ធផលការពិតណាមួយក្នុងអត្ថបទ ។ លទ្ធផលទាំងនេះគឺមិនបង្ហាញជាក់ស្តែងនៅក្នុងអត្ថបទនោះទេ។ ហើយលទ្ធផលខ្លះពិតខ្លះទៀតក៏មិនពិតដែរ ។

*ឧទាហរណ៍ ៖ តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកបានជំនួសអាតូមស្ពាន់ធ័រ ដោយអាតូមអុកស៊ីសែន នៅក្នុង រូបមន្ត $H_2S$ ?*

[4] http://www.teacherstoolbox.co.uk/25_Ways/25ways-15-decisions2.html

ដៃគូនីមួយៗ ត្រូវតែសម្រេចចិត្ត ថាតើបណ្ណមួយណាត្រឹមត្រូវ ហើយបណ្ណដែលមិនត្រឹមត្រូវតើវាមានបញ្ហាអ្វី?

ខាងក្រោមនេះគឺជាឧទាហរណ៍លំហាត់ **ការសម្រេចចិត្ត-ការសម្រេចចិត្ត** សម្រាប់មេរៀនគីមីវិទ្យាមួយស្ដីពីវ៉ាឡង់៖

## អត្ថបទ[5]

ក្នុងគីមីវិទ្យា វ៉ាឡង់ នៃធាតុមួយត្រូវបានបង្កើតឡើងពីថាមពលបញ្ចូលគ្នាជាមួយអាតូមផ្សេងទៀត នៅពេលដែលវាបង្កើតបានជា សមាសធាតុគីមី ឬម៉ូលេគុល។ បញ្ញត្តិនៃវ៉ាឡង់នេះ ត្រូវបានបង្កើតឡើងនៅពាក់កណ្ដាលទី២ នៃសតវត្សរ៍ទី១៩ និងទទួលបានជោគជ័យក្នុងការពន្យល់អំពីរចនាសម្ព័ន្ធម៉ូលេគុលនៃសមាសធាតុអសរីរាង្គ និងសមាសធាតុសរីរាង្គ។ ថាមពលអាតូមនៃធាតុមួយរួមបញ្ចូលគ្នាត្រូវបានកំណត់ដោយចំនួននៃអាតូមអ៊ីដ្រូសែនដែលវាបានបញ្ចូលជាមួយ។ ក្នុងមេតាន កាបូនមានវ៉ាឡង់ ៤ និងក្នុងអាម៉ូញាក់ អាសូតមានវ៉ាឡង់ ៣។ ក្នុងអ៊ីដ្រូសែនស៊ុលហ្វីដ ស្ពាន់ធ័រមានវ៉ាឡង់២។ ដ្យាក្រាមវ៉ាឡង់នៃសមាសធាតុ តំណាងឱ្យការតភ្ជាប់គ្នានៃធាតុដែលហៅថា**សមាសធាតុ** ជាមួយនឹងគំនូសបន្ទាត់រវាងធាតុទាំងពីរ ដែលតំណាងឱ្យការដាក់ចូលគ្នារវាងវ៉ាឡង់សម្រាប់ធាតុនីមួយៗ។ ខាងក្រោម នេះជាឧទាហរណ៍មួយចំនួន៖

| | | | | |
|---|---|---|---|---|
| **សមាសធាតុ** | $H_2$ (Hydrogen) អ៊ីដ្រូសែន | $CH_4$ (Methane) មេតាន | $NH_3$ (Ammonia) អាម៉ូញាក់ | $H_2S$ (Hydrogen Sulfide) អ៊ីដ្រូសែនស៊ុលហ្វីដ |
| **ដ្យាក្រាម** |  |  |  |  |
| **វ៉ាឡង់** | អ៊ីដ្រូសែន១ | កាបូន៤ អ៊ីដ្រូសែន១ | អាសូត ៣ អ៊ីដ្រូសែន១ | ស្ពាន់ធ័រ២ អ៊ីដ្រូសែន១ |

[5]https://en.wikipedia.org/wiki/Valence_(chemistry)

**សេចក្តីណែនាំ៖** ដោយផ្អែកទៅលើការយល់ដឹងរបស់អ្នកទៅលើអត្ថបទខាងលើ នៅក្នុងក្រុមរបស់អ្នកសូម កំណត់បណ្ណការពិតសង្ខេបមួយណាដែលខុស និងមូលហេតុដែលនាំឱ្យខុស ។ បន្ទាប់មក ទស្សន៍ទាយលទ្ធផលនៃលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងបណ្ណលទ្ធផល។

| បណ្ណការពិតសង្ខេប | បណ្ណលទ្ធផល |
|---|---|
| ១. គំនិតនៃវ៉ាឡង់នេះបានទទួលជោគជ័យក្នុងការពន្យល់អំពីរចនាសម្ព័ន្ធម៉ូលេគុលនៃសមាសធាតុសរីរាង្គ។ | ក. តើមានអ្វីកើតឡើងប្រសិនបើអ្នកជំនួសអាតូមស្ពាន់ធ័រ ដោយអាតូមអុកស៊ីសែននៅក្នុង $H_2S$? |
| ២. ពាក្យថាវ៉ាឡង់សំដៅទៅលើការភ្ជាប់គ្នារវាងអាតូមនិងអាតូម | ខ. តើនឹងមានអ្វីកើតឡើងទៅលើម៉ូលេគុលមេតាន ប្រសិនបើដកអាតូមកាបូនចេញ? |
| ៣. ជាធម្មតា វ៉ាឡង់ត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌនៃចំនួនអប្បបរមារបស់អាតូមអ៊ីដ្រូសែន ដែលធាតុមួយអាចភ្ជាប់ជាមួយបាន។ | គ. តើមានអ្វីកើតឡើងដល់ស្ថេរភាពនៃ ម៉ូលេគុលរបស់អាម៉ូញាក់ $NH_3$ ប្រសិនបើអ្នកដកអាតូមអ៊ីដ្រូសែនមួយចេញ? |
| ៤. វ៉ាឡង់ គឺបញ្ញត្តិថ្មី។ | ឃ. តើមានអាតូមផ្សេងទៀតដែរឬទេ ដែលអាចជំនួសស្ពាន់ធ័រក្នុង $H_2S$ ? តើនឹងផលិតបានអ្វី? |

### ជីក-ស ( Jigsaw)៖ វិធីសាស្រ្តសិក្សាបែបសហការ

ជីក-ស គឺជាវិធីសាស្រ្តសិក្សាបែបសហការមួយ ដែលមានប្រសិទ្ធិភាពខ្ពស់។

- ចែកប្រធានបទមួយ ឱ្យទៅប្រធានបទតូចៗ ៤។ ចំនួនប្រធានបទតូចៗ អាចមានច្រើនឬតិចជាងនេះអាស្រ័យលើទំហំថ្នាក់របស់អ្នក។ ឧទាហរណ៍ ជំងឺក្នុងតំបន់ត្រូពិច ដែលមានជំងឺផ្សេងគ្នាអាចនឹងត្រូវបានបែងចែកទៅជា (ក) រាគមួល (ខ) ជំងឺគ្រុនឈាម (គ) គ្រុនចាញ់ និង (ឃ) គ្រុនពោះវៀន។







- ជម្រើសផ្សេងទៀត៖ ផ្តល់ឱ្យសិស្សនូវសំណួរគន្លឹះ ឬ "ទស្សនៈ"ផ្សេងគ្នាចំនួន ៤ ដែលតម្រូវឱ្យសិស្សវិភាគលើប្រធានបទដូចគ្នា តែទៅលើផ្នែកផ្សេងៗពីគ្នា។ ឧទាហរណ៍៖ សិស្សទាំងអស់ត្រូវបានផ្តល់ព័ត៌មានពីសម័យអាណានិគមបារាំងដូចគ្នា ប៉ុន្តែបន្ទាប់មកបានត្រូវគេសួរដើម្បីវាយតម្លៃផ្សេងគ្នា ពី (ក) កសិករកម្ពុជា (ខ) អ្នកគ្រប់គ្រងកម្ពុជា (គ) អ្នកគ្រប់គ្រងបារាំង និង (ឃ) ព្រះមហាក្សត្រនៃប្រទេសកម្ពុជា។ នេះជាការវាយតម្លៃដែលគួរឱ្យចាប់អារម្មណ៍មួយ ព្រោះសិស្សត្រូវបង្កើតស្តង់ដានៃការវិនិច្ឆ័យផ្សេងគ្នាចេញពីក្រុមនីមួយៗ និងឆ្លើយតបទៅនឹងសំណួររួមមួយគឺ បារាំងបានធ្វើអ្វីខ្លះក្នុងអំឡុងពេលសម័យអាណានិគម?
- ចែកសិស្សជា ៤ ក្រុម។ គ្រូជ្រើសរើសក្រុមដែលមានសមត្ថភាពចម្រុះ បទពិសោធន៍ផ្សេងគ្នា ភេទ ជាតិសាសន៍ចម្រុះជាដើម។ កុំរើសក្រុមផ្អែកលើមិត្តភាព ។ សិស្សនឹងតវ៉ានៅលើកដំបូង ប៉ុន្តែពួកគេនឹងសម្របបានប្រសិនបើអ្នកនៅតែទទូចឱ្យពួកគេចូលរួម។
- ក្រុមនីមួយៗសិក្សាពីជំងឺឬសំណួរមួយដោយមានជំនួយពីអត្ថបទ និងសន្លឹកកិច្ចការ។ល។ ទោះបីជាអ្នកអាចប្រើវិធីសាស្ត្រនេះសម្រាប់សិស្សដើម្បីសិក្សានៅខាងក្រៅពេលម៉ោងសិក្សាក៏ដោយ ជាធម្មតាគេប្រើវានៅក្នុងម៉ោងសិក្សាប៉ុណ្ណោះ។ (សូមមើលការស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណែតក្នុងឯកសារចែកទី៩) ។
- ឥឡូវសិស្សសិស្សពីក្រុមនីមួយៗ ត្រូវចូលរួមបង្កើតក្រុមថ្មីទៀតទៅតាមប្រធានបទដែលគេទទួលខុសត្រូវដោយមានសិស្សម្នាក់ មកពីក្រុមនីមួយៗផ្សេងគ្នា។ សិស្សទាំងឡាយណាដែលលើសចំនួនគឺធ្វើជាដៃគូនៅក្នុងក្រុម។ ឥឡូវនេះក្រុមនីមួយៗក្លាយជា “ក្រុមជំនាញ” នៃជំងឺតំបន់ត្រូពិចមួយ។ (អាចមានអ្នកជំនាញពីរនាក់នៅក្នុងជំងឺមួយ)។

## ដំណើរការជីក-ស៖ ជំងឺត្រូពិច

**ជំហាន១៖ ស្រាវជ្រាវ**

ក្រុមនីមួយៗសិក្សាពីជំងឺមួយ ទាក់ទងនឹង៖

- របៀបនៃការឆ្លង
- រោគសញ្ញា
- រយៈពេលរបស់វីរុសផ្ទុក
- ការការពារ
- ការព្យាបាល

**ជំហាន២៖ ជីក-ស** (Jigsaw)

មនុស្សម្នាក់ពីក្រុមនីមួយៗចូលរួមជាមួយក្រុមផ្សេងទៀតដើម្បីបណ្ដុះបណ្ដាលពួកគេស្ដីពីប្រធានបទជំងឺរបស់ពួកគេ។

ពួកគេត្រូវតែបង្កើតទម្រង់ម៉ាទ្រីចដែលសង្ខេបលក្ខណៈនៃជំងឺនីមួយៗ។ ក្រោយមកពួកគេត្រូវបំពេញសំណួរ **ជីក-ស** ដែលមានបង្ហាញក្នុងប្រអប់ខាងក្រោម។

| ក្រុម១ (រាកមួល) | ក្រុម២ (គ្រុនឈាម) |
|---|---|
| ☒ ☒ ☒<br>☒ ☒ ☒ | ☒ ☒ ☒<br>☒ ☒ ☒ |

| ក្រុម៣ (ជំងឺគ្រុនចាញ់) | ក្រុម៤ (គ្រុនពោះវៀន) |
|---|---|
| ☒ ☒ ☒<br>☒ ☒ ☒ | ☒ ☒ ☒<br>☒ ☒ ☒ |

→

| ក្រុមថ្មី១ (រាកមួល) | ក្រុមថ្មី២ (គ្រុនឈាម) |
|---|---|
| ☒ ☒ ☒<br>☒ ☒ ☒ | ☒ ☒ ☒<br>☒ ☒ ☒ |

| ក្រុមថ្មី៣ (ជំងឺគ្រុនចាញ់) | ក្រុមថ្មី៤ (គ្រុនពោះវៀន) |
|---|---|
| ☒ ☒ ☒<br>☒ ☒ ☒ | ☒ ☒ ☒<br>☒ ☒ ☒ |

☒ = អ្នកជំនាញ ជំងឺរាកមួល

☒ = អ្នកជំនាញ ជំងឺគ្រុនឈាម

☒ = អ្នកជំនាញ ជំងឺគ្រុនចាញ់

☒ = អ្នកជំនាញ ជំងឺគ្រុនពោះវៀន

- ក្រុមថ្មីបញ្ចប់សកម្មភាព តម្រូវឱ្យពួកគេទៅបង្រៀនដៃគូទៅវិញទៅមកអំពីជំងឺរបស់ពួកគេ ហើយតម្រូវឱ្យពួកគេសហការជាមួយក្រុមផ្សេងទៀត លើកិច្ចការបញ្ចូលគ្នាដែលតម្រូវឱ្យបញ្ចូលគ្នានូវប្រធានបទទាំង៤ ។ ឧទាហរណ៍ សិស្សត្រូវធ្វើកិច្ចការខាងក្រោម៖

**សំណួរ ជីក-ស (Jigsaw)**

- ពន្យល់ពីជំងឺរបស់អ្នកទៅក្រុមថ្មីរបស់អ្នកដែលនៅសេសសល់ ដោយពន្យល់ដូចគ្នានូវកិច្ចការដែលបានធ្វើខាងដើម។ (ពេល ផ្ទុកមេរោគ របៀបចម្លង ។ល។)

  ______________________________

  ______________________________

  ______________________________

- សហការក្នុងការស្វែងរកចំណុចបីដែលជំងឺទាំងអស់មានសណ្ឋានរួមគ្នា។

  ______________________________

  ______________________________

  ______________________________

- សម្រាប់ជំងឺទាំងបួន សហការគ្នាដើម្បីស្វែងរកលក្ខណៈពិសេសឱ្យបានចំនួនបួន។

  ______________________________

  ______________________________

  ______________________________

- ផលិតខិត្តបណ្ណស្តីពីជំងឺតំបន់ត្រូពិច។ រៀបជំងឺទាំងបួនដាក់តាមលំដាប់៖

  A) ភាពធ្ងន់ធ្ងរនៃផលវិបាក

  B) ភាពងាយស្រួលក្នុងការការពារ

## លំហាត់

ប្រើការពន្យល់ដែលបានផ្តល់ជូនខាងលើ និងប្រើប្រាស់សៀវភៅសិក្សាគោលដែលផ្តល់ឱ្យដោយអ្នកសម្របសម្រួលបង្កើតសំណួរ ឬលំហាត់ផ្សេងៗ តាមគោលវិធីសិក្សាបែបស្ថាបនានិយម ដោយប្រើបច្ចេកទេស Decisions-Decisions ឬបច្ចេកទេស Jigsaw។ ត្រូវពន្យល់ពីសំណួរ ឬលំហាត់នោះ ឱ្យបានលម្អិតដោយផ្តល់ជាឧទាហរណ៍ជាគំរូ ដែលសិស្សនឹងអាចឆ្លើយបាន។

# ឯកសារចែកទី៧៖ វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហា ដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម[6]

**និយមន័យ៖** ការសិក្សាអាស្រ័យលើបញ្ហា (PBL) គឺជាបច្ចេកទេសសិក្សាតាមបែបស្ថាបនានិយម ដែលសិស្សនឹងរៀនអំពីមុខវិជ្ជាតាមរយៈបទពិសោធន៍នៃការដោះស្រាយបញ្ហាទូទៅ។ សិស្សរៀនទាំងវិធីនៃការគិត និងផ្នែកចំណេះដឹង។

**ដំណើរការ៖** ពេលធ្វើការជាក្រុម សិស្ស (ក) កំណត់អ្វីដែលពួកគេបានដឹងរួចហើយ (ខ) កំណត់អ្វីដែលពួកគេត្រូវដឹង និង (គ) របៀប និងកន្លែងដែលសិស្សស្រាវជ្រាវយកព័ត៌មានថ្មីដែលនាំទៅរកដំណោះស្រាយបញ្ហា។ តួនាទីរបស់គ្រូ គឺជួយសម្រួលដល់ការសិក្សាដោយផ្តល់ការគាំទ្រ ណែនាំ និងតាមដានការសិក្សារបស់សិស្ស។ គ្រូបង្រៀនត្រូវតែធ្វើឱ្យសិស្សមានទំនុកចិត្តក្នុងការទទួលយកបញ្ហា ព្រោះវាអាចជួយពង្រីកការយល់ដឹងរបស់ពួកគេបាន។ PBL តំណាងឱ្យការផ្លាស់ប្តូរគំរូពីការបង្រៀនតាមបែបប្រពៃណី និងទស្សនវិជ្ជាបង្រៀនដោយផ្តោតទៅលើសកម្មភាពគ្រូច្រើន និងសន្មតថាសិស្សរៀនបានច្រើនពេលដែលពួកគេបានស្តាប់ច្រើន។

## ឧទាហរណ៍៖

*សេចក្តីណែនាំ៖ រូបភាពខាងក្រោមនេះបានបង្ហាញពីឈុតឆាកមួយពីការសាងសង់មហាកំផែងចិន ដែលបានសាងសង់ឡើងដោយអធិរាជ Qin Shihuang អំឡុងឆ្នាំ ២២០ មុនគ.ស។ មាន កំហុសចំនួន៧ ក្នុងរូបភាពនេះដែលខុសពីប្រវត្តិសាស្ត្រ។ ដោយផ្អែកលើចំណេះដឹងរបស់អ្នក ចូរកំណត់កំហុសទាំង៧ ដែលមិនត្រឹមត្រូវ និងធ្វើការបកស្រាយពីមូលហេតុដែលខុស។*



[6]https://en.wikipedia.org/wiki/Problem-based_learning

## សំណួរពិភាក្សា

*ក្នុងក្រុមរបស់អ្នក ចូរពិភាក្សាពីសំណួរខាងក្រោម និងរៀបចំរាយការណ៍ទៅក្រុមធំវិញ។*

១. តើអ្នកអាចរកឃើញកំហុសបានប៉ុន្មាន?

២. តើក្រុមរបស់អ្នកកំណត់អ្វីដែលបានដឹងរួចហើយដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា? (ឧទាហរណ៍៖ កាលបរិច្ឆេទសាងសង់មហាកំផែង និងបច្ចេកវិទ្យានាសម័យ ។ល។)។

៣. តើអ្នកបានកំណត់អ្វីដែលអ្នកត្រូវដឹងបន្ថែមដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា? (ឧទាហរណ៍៖ តើអ្វីដែលអ្នកដឹងមិនទាន់ច្បាស់នៅក្នុងរូបភាព ហើយត្រូវស្វែងយល់?)

៤. តើអ្នកបានកំណត់អ្វីដែលអ្នកមិនទាន់បានដឹងដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា?

**ចម្លើយ**[7]

១. ចិនបុរាណ មិនមាន រទេះរុញប្រភេទទំនើបនោះទេ។ ទោះបីជាពួកគេបានបង្កើតឧបករណ៍នេះមុនគេ ដែលគេហៅថា 'គោឈើ " ដែលបានបង្ហាញនៅក្នុងរូបភាពនេះក៏ដោយ ក៏ពួកគេមិនមានរទេះរុញដែលទំនើបដូចបច្ចុប្បន្ននោះទេ។

២. សិប្បករជនជាតិហាន-ចិនបានផលិតវត្ថុល្អៗជាច្រើនដូចជាសេះដែលធ្វើពីលង្ហិនដែលបានបង្ហាញក្នុងរូបភាពនេះ។ ប៉ុន្តែពួកគេមិនអាចធ្វើជាគំរូនៃប៉ម តួអេហ្វែល( Eiffel Tower ) ដែលទើបតែសាងសង់ក្នុងឆ្នាំ ១៨៨៩ នៅក្នុងប្រទេសបារាំង ដែលជាប្រទេសមួយចិនមិនទាន់ស្គាល់នៅពេលនោះទេ។

៣. ចិនបុរាណមិនបានប្រើលុយដែលមានសណ្ឋានដូចនេះទេ។ កាក់ចិនបុរាណ មានរាងមូល និងមានរន្ធនៅចំកណ្តាល។

៤. ក្មេងៗចិនមិនមានឡានជំរ លេងទេ នៅក្នុងសតវត្សរ៍ទី ៣ មុនគ.ស។

៥. ចិនបុរាណជាជាងឈើដ៏ចំណាន ប៉ុន្តែពួកគេមិនមានម៉ូទ័រស្វានប្រើអំឡុងពេលនេះទេ។

៦. យើងមិនអាចរកឃើញនិមិត្តសញ្ញារបស់ St. George ដែលជាអស្សឫទ្ធិប្រទេសអង់គ្លេស នៅលើផែនទីចិនបុរាណនោះទេ។ ប្រទេសអង់គ្លេសមិនទាន់កើតនៅឡើយនាពេលនោះ សូម្បីព្រះយេស៊ូគ្រិស ក៏មិនទាន់កើតផងដែរ។

៧. មិនមានផ្លូវដែកនៅក្នុងប្រទេសចិនទេពីមុនទេ វាទើបតែមាននៅចុងសតវត្សរ៍ទី១៩ ។ ក្នុងសតវត្សរ៍ទី៣ ទំនិញចិនត្រូវបានដឹកជញ្ជូនតាមបណ្តាញផ្លូវគោក និងផ្លូវទឹក។

---

[7] Wood, J. (1992) *Errata: A Book of Historical Errors,* New York: Green Tiger Press.

# ឯកសារចែកទី៨៖ ដំណើរការ និងផលិតផល នៃការសិក្សាបែបស្ថាបនានិយម

<table>
<tr><td rowspan="8">ឧទាហរណ៍ពីដំណើរការ និងផលិតផលសិក្សា តាមបែបស្ថាបនានិយម<br><br>បង្កើតបរិបទសម្រាប់ការសិក្សាបែបសកម្ម...</td><td></td><td>គម្រោងវិទ្យាសាស្ត្រ</td></tr>
<tr><td></td><td>ការងារគម្រោងជាក្រុម</td></tr>
<tr><td></td><td>ការតាំងពិព័រណ៍</td></tr>
<tr><td></td><td>បទបង្ហាញ</td></tr>
<tr><td></td><td>របាយការណ៍សៀវភៅ & ការនិពន្ធ</td></tr>
<tr><td></td><td>ការស្រាវជ្រាវតាមអ៊ីនធឺណែត</td></tr>
<tr><td></td><td>ទស្សនកិច្ចសិក្សា</td></tr>
<tr><td></td><td>កិច្ចការពិសោធន៍</td></tr>
</table>

## សំណួរសម្រាប់ពិភាក្សា

១. តើឧទាហរណ៍ណាខ្លះខាងលើ បង្ហាញពី "ដំណើរការ" ហើយមួយណាជា "ផលិតផល"? តើអ្នកដឹងដោយរបៀបណា?

២. ពិចារណាពី *គោលការណ៍នៃការសិក្សាបែបស្ថាបនានិយម* ដែលបានពិភាក្សានៅក្នុងឯកសារចែក ២ខ ។ ជ្រើសយកដំណើរការ / ផលិតផលមួយ ហើយពន្យល់មូលហេតុដែលទាក់ទងនឹងគោលការណ៍ស្ថាបនានិយមដោយបំពេញតារាងខាងក្រោម។
តើវាមានភាព *អន្តរកម្ម* ដោយរបៀបណា? តើវា *ជាក់ស្តែង* ដោយរបៀបណា? តើវាជា *ការសិក្សាបែបសម្របសម្រួល* ដោយរបៀបណា? តើវាលក្ខណៈជា *សិស្សមជ្ឈមណ្ឌល* ដោយរបៀបណា?

| សកម្មភាពសិក្សាបែបស្ថាបនានិយម | ផលិតផល ឬ ដំណើរការ | តើវាបង្ហាញពីគោលការណ៍ស្ថាបនានិយមដោយរបៀបណា ? |
|---|---|---|
| | - | - |

## លំហាត់

*សេចក្តីណែនាំ៖ រំឭកឡើងវិញនូវសកម្មភាពនីមួយៗ ហើយព្យាយាមកំណត់ការរៀបចំ ផ្សេងៗដើម្បីពង្រឹងស្ថាប័ន ដើម្បីឱ្យសកម្មភាពទាំងនោះកើតឡើងប្រកបដោយប្រសិទ្ធិភាព។*

| សកម្មភាពសិក្សាបែបស្ថាបនានិយម | តម្រូវការស្ថាប័ន |
|---|---|
| **គម្រោងវិទ្យាសាស្ត្រ** | - ការរៀបចំគ្រូវិទ្យាសាស្ត្រដែលបានស្ម័គ្រចិត្តប្រឹក្សាដល់ក្លឹបមុខវិជ្ជាវិទ្យាសាស្ត្រ<br>- ចិរកាសម្រាប់សម្ភារៈ<br>- ពេលវេលាគ្រប់គ្រាន់៖ ទាំងសកម្មភាពក្រៅថ្នាក់ ទាំងសកម្មភាពសិក្សាម៉ោងបន្ថែម<br>- មានសៀវភៅបំប៉នរបស់ក្លឹប |
| **គម្រោងការងារជាក្រុម** | - |

| | |
|---|---|
| ការតាំងពិព័រណ៍ | |
| បទបង្ហាញ | |
| សៀវភៅរបាយការណ៍ និង កំណាព្យ | |
| ការស្រាវជ្រាវតាមបណ្ដាញអ៊ីនធឺណែត | |
| ទស្សនកិច្ចសិក្សា | |
| កិច្ចការបន្ទប់ពិសោធន៍ | |

# ឯកសារចែកទី៩៖ ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា



**ការសិក្សាគឺការបង្កើតទំនាក់ទំនងសង្គម៖** **ប្រសិនបើកុមារអភិវឌ្ឍល្អប្រសើរក្នុងសង្គមឬក្រុមរបស់ពួកគេ នោះការប្រើប្រាស់បច្ចេកវិទ្យាដើម្បីភ្ជាប់ទំនាក់ទំនង អាចមានប្រសិទ្ធិភាពខ្ពស់។**

**ការអនុវត្តគោលការណ៍នេះ៖** ដោយផ្អែកលើគោលការណ៍ខាងលើ គ្រូដែលបង្រៀនបែបស្ថាបនានិយម គួរតែបង្កើតបរិបទសិក្សាមួយ ដែលសិស្សអាចចូលរួមក្នុងសកម្មភាពដោយមានការលើកទឹកចិត្ត និងជួយសម្រួលពីលោកគ្រូ អ្នកគ្រូ ។ ទោះជាយ៉ាងណា គ្រូមិនត្រូវឈរចាំមើលសិស្សសិក្សាស្វែងយល់ និងស្រាវជ្រាវមេរៀននោះទេ ផ្ទុយទៅវិញ គ្រូអាចដឹកនាំសិស្ស លើកទឹកចិត្តឱ្យពួកគេធ្វើការជាក្រុម ដើម្បីគិតពីបញ្ហា និងសំណួរ។ គ្រូគួរគាំទ្រពួកគេ តាមរយៈការលើកទឹកចិត្ត និងផ្តល់ប្រឹក្សាដើម្បីដោះស្រាយបញ្ហា ហានិភ័យ និងបញ្ហាប្រឈមដែលបានចាក់ឫសនៅក្នុងស្ថានភាពជីវិតពិតរបស់ពួកគេ ដែលជាកត្តាជំរុញឱ្យពួកគេចាប់អារម្មណ៍ និងពេញចិត្តនិងសកម្មភាពសិក្សាទាំងនេះ។



## បច្ចេកវិទ្យា និងការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម

បច្ចេកវិទ្យាផ្តល់ជាឧបករណ៍ដ៏សំខាន់ដើម្បីជួយសម្រេចគោលដៅនៃការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួននៃព័ត៌មានវិទ្យាដែលអាចជួយក្នុងការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម៖

- *ឧបករណ៍ទូរគមនាគមន៍* ដូចជាអ៊ីម៉ែល និងអ៊ីនធឺណែត ផ្តល់ជាមធ្យោបាយមួយសម្រាប់ការសន្ទនា ការពិភាក្សា ការជជែកដេញដោល និងអន្តរកម្មរវាងសិស្ស។ សិស្សអាចជជែកជាមួយសិស្សផ្សេងទៀត ជាមួយគ្រូ និងជាមួយគ្រូក្នុងសហគមន៍បាន បើទោះបីជាពួកគេនៅឆ្ងាយពីថ្នាក់រៀនរបស់ពួកគេក៏ដោយ។ ឧបករណ៍ទូរគមនាគមន៍អាចជួយផ្សាភ្ជាប់សិស្សជាមួយធនធានព័ត៌មានច្រើនប្រភេទបាន ហើយក៏អាចជួយពួកគេឱ្យយល់ទាំងវប្បធម៌របស់ខ្លួន និងវប្បធម៌របស់អ្នកដទៃ។
- *បទបង្ហាញជា PowerPoint៖* បទបង្ហាញដែលបង្កើតឡើងដោយសិស្សនៅក្នុងក្រុមរបស់ពួកគេក៏បានផ្តល់នូវបណ្តាញសង្គមដ៏មានប្រយោជន៍សម្រាប់សិស្សដើម្បីធ្វើការរួមគ្នាជាក្រុមក្នុង

ការផលិតជាផលិតផលសិក្សា ប្រកបដោយការច្នៃប្រឌិតដើម្បីចែករំលែកជាមួយសិស្សក្នុងថ្នាក់។ សាលារៀនគួរតែមានម៉ាស៊ីន LCD សម្រាប់បញ្ចាំង ដែលទាំងគ្រូនិងសិស្សអាចប្រើប្រាស់បានសម្រាប់គោលបំណងនេះ។

- ***សម្ភារៈបរិក្ខាភ្ជាប់អ៊ីនធឺណែតនៅក្នុងបណ្ណាល័យ៖*** ការបង្កើតសម្ភារៈបរិក្ខា ងាយស្រួលចូលប្រើអ៊ីនធ័រណែតនៅក្នុងបណ្ណាល័យជាមធ្យោបាយមួយទៀត ដើម្បីឱ្យសិស្សអាចធ្វើការជាមួយគ្នានៅលើកិច្ចការវិភាគ។ សម្ភារៈបរិក្ខានេះអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហាដែលគ្រូដាក់ឱ្យ ការអភិវឌ្ឍការងារគម្រោង ប្រភពនៃរូបភាព និងដ្យាក្រាមនានា ។




- ***កម្មវិធីសរសេរតាមបណ្តាញអ៊ីនធឺណែត៖*** ផ្តល់នូវវេទិកាតែមួយសម្រាប់ការសរសេរតាមបែបសហការ។ សិស្សអាចសរសេរសម្រាប់ទស្សនិកជនដែលពួកគេអាចឆ្លើយតបភ្លាមៗ និងសម្រាប់អ្នកដែលចូលរួមក្នុងសកម្មភាពសរសេរជាក្រុម។
- ***សកម្មភាពប្រឌិតអេឡិចត្រូនិក** (Electronic Simulation)* អាចធ្វើឱ្យការសិក្សាមានភាពទាក់ទាញ និងរស់រវើក ដោយបង្ហាញអ្វីមួយក្នុងបរិបទនៃសកម្មភាពដូច "ពិភពពិតប្រាកដ" ដូចជាដំណើរការរោងចក្រថាមពលនុយក្លេអ៊ែរ ការសរសេររឿងថ្មីៗក្នុងសារព័ត៌មានមួយ ឬការដោះស្រាយជាមួយនឹងបញ្ហាបំពុលទឹកក្នុងតំបន់។

# ឯកសារចែកទី១០៖ ការវាយតម្លៃផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម

**ការណែនាំ៖** ចូរអានការសន្ទនាខាងក្រោមនិងចូលរួមក្នុងការពិភាក្សាជាមួយក្រុមរបស់អ្នក ដើម្បីឆ្លើយសំណួរខាងក្រោម៖




## សំណួរពិភាក្សា

១. តើកម្រិតនៃការគិតមានលក្ខណៈយ៉ាងដូចម្តេច ចំពោះការវាយតម្លៃក្នុងរូបភាព ក? រូបភាព ខ? ចូរគិតអំពីសំណួរតាក់សូណូមីប្លូមដើម្បីរកចម្លើយរបស់អ្នក។

២. វាយគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រវាយតម្លៃដែលមានទាំងក្នុងរូបភាព ក និងរូបភាព ខ។

៣. ហេតុអ្វីបានជាអ្នកគិតថា គ្រូបង្រៀននៅកម្ពុជាមិនប្រើយុទ្ធសាស្ត្រវាយតម្លៃដែលមាននៅក្នុងរូបភាព ខ?

# ឯកសារចែកទី ១១៖ យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម

## គំនិតសំខាន់ៗមួយចំនួន

- ក្នុងអំឡុងពេលវាយតម្លៃ គ្រូបង្រៀនសិក្សាបែបស្ថាបនានិយមតែងតែមានការចាប់អារម្មណ៍ទៅលើ " របៀប" ដែលកុមារបានទាញការសន្និដ្ឋាន ឬ រកចម្លើយជាជាងលទ្ធផលចម្លើយ។
- ដំណើរការនៃការរៀនសូត្រគឺសំខាន់ដូចគ្នានឹង ផលិតផលសិក្សាដែរ។
- ការវាយតម្លៃតាមបែបប្រពៃណី និងការធ្វើតេស្តស្តង់ដាមិនមានប្រយោជន៍សម្រាប់ការវាយតម្លៃការសិក្សាបែបស្ថាបនានិយមនោះទេ។
- ដោយសារសាលារៀនភាគច្រើនត្រូវធ្វើការក្នុងបរិបទដែលការធ្វើតេស្តផ្លូវការមិនអាចជៀសរួច គ្រូបង្រៀនត្រូវតែមានគំនិតច្នៃប្រឌិតក្នុងការសំយោគបច្ចេកទេសវាយតម្លៃបែបថ្មីនេះទៅក្នុងប្រព័ន្ធដែលមានស្រាប់។

វិធីសាស្ត្រល្អៗ មួយចំនួនសម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម



# បច្ចេកទេសសម្រាប់ការវាយតម្លៃ[8]

អ្នកសិក្សាទ្រឹស្តីខាងការសិក្សាបែបស្ថាបនានិយម ផ្តល់នូវវិធីសាស្ត្រផ្សេងៗគ្នាចំនួន៤ សម្រាប់វាយតម្លៃសិស្សនៅក្នុងបរិយាកាសសិក្សាបែបស្ថាបនានិយម។ យុទ្ធសាស្ត្រទាំងនេះមានភាពត្រួតគ្នាខ្លះៗ ប៉ុន្តែវិធីនីមួយៗក៏មានរបៀបជាក់លាក់របស់វាផងដែរ។

- **ការវាយតម្លៃបែបឌីណាមិចៈ** វិធីសាស្ត្រនេះអនុវត្តដោយគ្រូ ដែលចេះដាក់បញ្ចូលការវាយតម្លៃទៅក្នុងដំណើរការបង្រៀនតាមដែលអាចធ្វើទៅបាន។ បច្ចេកវិទ្យាអាចប្រើសម្រាប់ការបញ្ចូល "ការវាយតម្លៃបែបឌីណាមិច" ជាប្រចាំទៅក្នុងសម្ភារៈសិក្សា (ឧ. មីឌៀសង្គម អ៊ីម៉ែល។ ល។ ) ។ ការវាយតម្លៃអាចត្រូវបានដាក់បញ្ចូលទៅក្នុងបទពិសោធន៍នៃការរៀនសូត្រ ដែលមានអត្ថន័យពេញលេញ និងមិនត្រូវបានយកមកប្រើនៅចុងបញ្ចប់ឡើយ។ ការវាយតម្លៃប្រភេទនេះទាមទារឱ្យគ្រូបង្រៀនមានទំនាក់ទំនងផ្ទាល់ជាមួយសិស្សក្នុងអំឡុងពេលវាយតម្លៃ។
- **ការវាយតម្លៃកម្រងស្នាដៃសិស្សៈ** នៅក្នុងបច្ចេកទេសនេះ គ្រូបង្រៀនធ្វើការរិះគន់ និងពិភាក្សាអំពីផលិតផលសិក្សាដែលបានបង្កើតឡើងនៅក្នុងបរិបទជាក់ស្តែងរួមមានកម្រងស្នាដៃសិស្ស គម្រោងការតែងនិពន្ធ ការសម្តែង និងតេស្តនៅផ្ទះ។ ការប្រើប្រាស់ផលិតផលការងារអាចបំពេញនូវវិធានការវាយតម្លៃបែបប្រពៃណីបានច្រើននៃការទទួលបានចំណេះដឹង និងការយល់ដឹង។
- **ការវាយតម្លៃបែបដំណើការៈ** នៅក្នុងបច្ចេកទេសនេះ គ្រូបង្រៀនវាយតម្លៃទាំងដំណើរការ និងផលិតផល។ យុទ្ធសាស្ត្រមួយចំនួនដែលបញ្ជាក់ដោយបច្ចេកទេសនេះរួមមានៈ ការសាកសួរ បញ្ជីត្រួតពិនិត្យផ្ទៀងផ្ទាត់ ការសម្ភាស ការពិភាក្សាជាក្រុម ការប្រាប់ពីចំណេះដឹង ការស៊ើបអង្កេត និងសកម្មភាពដោះស្រាយបញ្ហា។
- **ការវាយតម្លៃក្រៅផ្លូវការៈ** ការវាយតម្លៃក្រៅផ្លូវការសំដៅទៅលើការសង្កេតរបស់គ្រូបង្រៀនដោយប្រើភ្នែកផ្ទាល់ ភាសាកាយវិការ ការបង្ហាញទឹកមុខ និងការអនុវត្តការងារ។ ការសង្កេតទាំងនេះអាចបំពេញបន្ថែមនូវការវាយតម្លៃផ្លូវការដែលជាមូលដ្ឋានសម្រាប់ការកែតម្រូវការបង្រៀន។




[8] https://etad.usask.ca/802papers/Skaalid/eval.html

## ឯកសារចែកទី ១២៖ ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម

| យុទ្ធសាស្ត្រវាយតម្លៃ | ឧទាហរណ៍ & សេចក្តីពន្យល់ |
|---|---|
| **ការវាយតម្លៃបែបឌីណាមិច**<br><br> | ✚ ឧ. ការចាត់តាំងការងារឱ្យក្រុមវិទ្យាសាស្ត្រដែលសិស្សត្រូវរៀបចំពិសោធន៍ផ្ទាល់ខ្លួនដើម្បីបង្ហាញគោលការណ៍ជាក់លាក់ដែលបានរៀននៅក្នុងថ្នាក់។ គ្រូបង្រៀនវាយតម្លៃតាមរយៈការធ្វើអន្តរកម្មជាមួយសិស្សក្នុងអំឡុងពេលដំណើរការ ដើម្បីវាស់ស្ទង់ការធ្វើការជាក្រុមនិងការយល់ដឹងរបស់ពួកគេ។<br>✚ **តួនាទីរបស់គ្រូបង្រៀន៖**<br>○ ធ្វើអន្តរកម្មជាមួយសិស្សដើម្បីកំណត់ថាតើពួកគេធ្វើការជាមួយគ្នាជាក្រុមបានល្អប៉ុណ្ណា។<br>○ កំណត់ថាតើសិស្សអាចអនុវត្តការស្រាវជ្រាវដែលចាំបាច់ឬអត់។<br>○ សម្ភាសសិស្សដើម្បីកំណត់ពីរបៀបដែលពួកគេសម្រេចបានផលិតផលចុងក្រោយរបស់ពួកគេ។<br>○ ពិនិត្យឡើងវិញនូវមីខៀសង្គមឬអ៊ីម៉ែលទំនាក់ទំនងដើម្បីកំណត់ការយល់ដឹងស៊ីជម្រៅរបស់សិស្សនៅក្នុងក្រុម។<br>○ គ្រូបង្រៀនគួរកត់ចំណាំរាល់អន្តរកម្មទាំងអស់របស់ពួកគេហើយប្រើលក្ខណៈទាំងនេះដើម្បីជួយសិស្សនៅពេលក្រោយ។ |
| **ការវាយតម្លៃលើកម្រងស្នាដៃសិស្ស**<br><br> | ✚ ឧ. សិស្សត្រូវតែសរសេរជាលក្ខណៈបុគ្គលនូវកំណាព្យជាភាសាខ្មែរដោយប្រើក្បួនខ្នាតតែងកំណាព្យច្រើនប្រភេទ។ គ្រូបង្រៀនវាយតម្លៃដោយពិនិត្យមើលផលិតផល និងនិយាយជាមួយសិស្ស បន្ទាប់ពីផលិតផលកម្រងស្នាដៃរបស់ពួកគេត្រូវបានបញ្ចប់។<br>✚ **តួនាទីរបស់គ្រូបង្រៀន៖** |

| យុទ្ធសាស្ត្រវាយតម្លៃ | ឧទាហរណ៍ & សេចក្តីពន្យល់ |
|---|---|
| | ○ ផ្តល់សម្ភារៈសម្រាប់ឱ្យសិស្សរក្សាទុក / ចងក្រងកំណាព្យរបស់ពួកគេ<br>○ អនុញ្ញាតឱ្យសិស្សធ្វើការលើគម្រោងរបស់ពួកគេក្រៅថ្នាក់។<br>○ ផ្តល់សម្ភារធនធានដើម្បីជួយសិស្សធ្វើគម្រោងរបស់ពួកគេ។<br>○ ពិនិត្យឡើងវិញនូវផលិតផលអក្សរសាស្ត្រជាមួយសិស្សនិងសួរសំណួរអំពីរបៀបដែលពួកគេកំណត់ខ្លឹមសារ អ្វីដែលងាយស្រួល អ្វីដែលពិបាក។ ល។<br>○ ចាត់តាំងកម្រិត (ពិន្ទុ) ផ្អែកលើលទ្ធផល និងការសម្ភាសបែបអន្តរកម្មជាមួយសិស្ស។ |
| **ការវាយតម្លៃបែបដំណើរការ**<br> | ✚ ឧ. សិស្សបង្កើតគម្រោងគណិតវិទ្យាដែលយកគំរូពីគោលការណ៍សំខាន់ៗមួយចំនួន។ គម្រោងនេះនឹងត្រូវបានបង្ហាញនៅលើក្តារព័ត៌មានក្នុងថ្នាក់។ គ្រូបង្រៀនបានជួបជាមួយសិស្សជាទៀងទាត់ដើម្បីពិភាក្សាអំពីគម្រោងនិងធ្វើការវាយតម្លៃ។<br>✚ **តួនាទីរបស់គ្រូបង្រៀន៖**<br>○ គ្រូបង្រៀនគួរតែផ្តល់ប៉ារ៉ាម៉ែត្រទូលំទូលាយនៃគម្រោងដល់សិស្សប៉ុន្តែអនុញ្ញាតឱ្យពួកគេកំណត់ខ្លឹមសារដែលនឹងត្រូវយកមក។<br>○ គ្រូបង្រៀនធ្វើការពិភាក្សាជាទៀងទាត់ជាមួយសិស្សដើម្បីមើលថាតើពួកគេកំពុងរីកចម្រើនជាមួយគម្រោងយ៉ាងដូចម្តេច។<br>○ គ្រូបង្រៀនប្រើតារាងត្រួតពិនិត្យផ្ទៀងផ្ទាត់ដើម្បីកត់ចំណាំអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានាហើយរួមបញ្ចូលការសង្កេតទាំងនេះនៅក្នុងការវាយតម្លៃចុងក្រោយនៃគម្រោង។ |

| **យុទ្ធសាស្រ្តវាយតម្លៃ** | **ឧទាហរណ៍ & សេចក្តីពន្យល់** |
|---|---|
| ការវាយតម្លៃក្រៅផ្លូវការ<br><br> | - ឧ. គ្រូបង្រៀនអញ្ជើញសិស្សឱ្យជជែកវែកញែកជាភាសាអង់គ្លេសលើប្រធានបទដែលពួកគេជ្រើសរើស។ បន្ថែមពីលើការសង្កេតមើលថាតើក្រុមជជែកវែកញែកនីមួយៗជជែកគ្នាពីចំណុចណាមួយនៃអំណះអំណាងរបស់ពួកគេ គ្រូបង្រៀនធ្វើការសង្កេតជាក់ស្តែងលើផ្ទៃមុខរបស់សិស្ស កម្រិតថាមពល និងការចូលរួម។<br>- **តួនាទីរបស់គ្រូបង្រៀន៖**<br>  ○ គ្រូបង្រៀនសង្កេតការជជែកវែកញែកដែលត្រូវបានចាត់តាំងឱ្យសិស្ស។<br>  ○ បន្ថែមលើបញ្ជីត្រួតពិនិត្យផ្ទៀងផ្ទាត់ដែលគ្រូបង្រៀនអាចប្រើដើម្បីវាយតម្លៃការប្រើប្រាស់បច្ចេកទេសជជែកវែកញែកសមស្រប គ្រូបង្រៀនក៏ត្រូវធ្វើកំណត់ចំណាំអំពីទឹកមុខរបស់សិស្ស កម្រិតថាមពល និងការចូលរួមផងដែរ។<br>  ○ ការសង្កេតក្រៅផ្លូវការត្រូវបានផ្សំជាមួយនឹងការវាយតម្លៃដែលផ្តោតលើដំណើរការជាផ្លូវការបន្ថែមទៀត (ឧ. ពិន្ទុបញ្ជីផ្ទៀងផ្ទាត់) ដើម្បីធ្វើការវាយតម្លៃរួមនៃការរៀននិងការសម្តែងសមត្ថភាព។ |

## ការពិភាក្សាក្រុមតូច

នៅក្នុងក្រុមតូច សូមចូលរួមក្នុងការពិភាក្សាអំពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងយុទ្ធសាស្ត្រវាយតម្លៃផ្សេងៗដែលបានពិពណ៌នានៅក្នុងតារាងខាងលើ។ បន្ទាប់មកសូមបញ្ចូលតារាងខាងក្រោមដែលសង្ខេបថាតើបច្ចេកទេសទាំងនេះមានលក្ខណៈស្រដៀងគ្នា និងខុសគ្នាបែបណាខ្លះ?

| **កត្តា** | **ការវាយតម្លៃបែបឌីណាមិច** | **ការវាយតម្លៃលើកម្រងស្នាដៃសិស្ស** | **ការវាយតម្លៃបែបដំណើរការ** | **ការវាយតម្លៃក្រៅផ្លូវការ** |
|---|---|---|---|---|
| **ពេលវេលា**<br>(ឧ. មុន អំឡុងពេល ចុងបញ្ចប់នៃកិច្ចការ) | | | | |
| **ការផ្តោតលើផលិតផល** (ឧ. ខ្ពស់ ទាប ។ល។) | | | | |
| **ការផ្តោតលើដំណើរការ** (ឧ. ខ្ពស់ ទាប ។ល។) | | | | |
| **អន្តរកម្មគ្រូបង្រៀន** (ឧ. ខ្ពស់ ទាប ។ល។) | | | | |
| **ប្រើបច្ចេកទេសវាយតម្លៃផ្លូវការ** (ឧ. បញ្ជីផ្ទៀងផ្ទាត់ តេស្ត ។ល។) | | | | |